00184872

C22/I/26

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ០៣) |
| **ដាក់ទៅ:** | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់:** | ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨ |
| **ភាគីអ្នកដាក់:** | មេធាវីការពារក្ដីលោក អៀង សារី |
| **ភាសាដើម:** | អង់គ្លេស |
| **ប្រភេទឯកសារ:** | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សារណារបស់លោក អៀង សារី អនុលោមតាម *សេចក្ដីសម្រេចអំពីសំណើជាបន្ទាន់ របស់ សហមេធាវី សុំការពន្យាពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ*

<u>អ្នកដាក់ឯកសារ:</u>

**មេធាវីរបស់លោក អៀង សារី**

លោកមេធាវី អាង ឧត្ដម

លោកមេធាវី Vichael G. KARNAVAS

<u>អ្នកទទួលឯកសារ:</u>

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ផុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETI

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ORIGINAL EN: 00177265-00177280

00184873



C22/I/26

# I. សេចក្ដីផ្ដើម

1. លោក **អៀង សារី** តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន (“**មេធាវីការពារ**”) ពេលនេះ សុំដាក់ស្នើសារណារបស់ខ្លួនអំពី បញ្ហាយុត្តាធិការ ដែលត្រូវបានលើកឡើងដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេត ( “ក.ស.ច.ស.”) ក្នុងកថាខណ្ឌ ៥ ដល់ ១៤ នៃ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន[1] ស្របតាមសេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះ (“**អ.ប.ជ.**”)[2] ។

2. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ខ្លួន ក.ស.ច.ស. បានសម្រេចថា ទោះគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ *(ne bis in idem)* ក្ដី ឬ ព្រះរាជទានលើកលែងទោសនិងអនុគ្រោះទោស (“**ព្រះរាជក្រិត្យលើកលែងទោស**”) ដែលផ្ដល់ឲ្យលោក **អៀង សារី** កាលពីឆ្នាំ ១៩៩៦ ក្ដី ក៏មិនរារាំង នាពេលបច្ចុប្បន្ន ដល់ការចោទប្រកាន់លើរូបលោក **អៀង សារី** បានឡើយ[3]។ ក.ស.ច.ស. បានពឹងផ្អែកទៅលើការសម្រេចរបស់ខ្លួនថា *ne bis in idem* មិនរារាំងដល់ការចោទប្រកាន់នេះ ព្រោះថា នាពេលបច្ចុប្បន្ន លោក **អៀង សារី** មិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ[4] ហើយបានធ្វើការកត់សំគាល់ថែមទៀតថា ការកាត់ទោសត្រួតគ្នា ត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ[5] ហើយថា សវនាការរឿងក្ដីកាលពីឆ្នាំ ១៩៧៩ មិនបានគ្របដណ្ដប់លើបទល្មើសទាំងអស់ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ឡើយ[6]។ ក.ស.ច.ស. បានសម្រេចថា **ព្រះរាជក្រិត្យលើកលែងទោស** នោះមិនគួររារាំងដល់ការចោទប្រកាន់ទេ ដោយហេតុថា ការលើកលែងទោសនោះគឺយោងសំដៅទៅលើ ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជា

---

[1] ករណី អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

[2] ករណី អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អបជ(៣) សេចក្ដីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីលោក អៀង សារី ក្នុងការស្នើសុំពន្យាពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០៨ “សហមេធាវីអាចដាក់សារណាមិនឲ្យលើសពី ១៥ទំព័រ អំពីបញ្ហាយុត្តាធិការដែលបានលើកឡើងក្នុងកថាខណ្ឌទី ៥ ដល់ទី ១៤ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន...”)

[3] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ៧ ដល់ទី ១៤ ។

[4] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ៨ ។

[5] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ៩ ។

[6] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ១០ ។

ប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ("ច្បាប់ឆ្នាំ ១៩៩៤")[7] ហើយថា ច្បាប់ឆ្នាំ ១៩៩៤ នោះមិនគ្រប ដណ្ដប់លើបទល្មើសទាំងឡាយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក.[8] ឡើយ។

3. មេធាវីការពារសុំលើកឡើងថា អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការជំនុំជម្រះរឿងលោក**អៀង សារី** ចំពោះបទឧក្រិដ្ឋនានា ដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះឡើយ[9]។ អនុលោមទៅតាមសេចក្ដីសម្រេចរបស់អ.ប.ជ មេធាវីការពារក្ដីត្រូវបានកម្រិតក្នុងការធ្វើសារណា ជូនសម្អាងរបស់ខ្លួន ដោយឆ្លើយតបតែទៅលើការអះអាងដែលធ្វើឡើងដោយ ក.ស.ច.ស នៅក្នុង កថាខ័ណ្ឌ ៥ ដល់ ១៤ នៃ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នប៉ុណ្ណោះ។ ចំណុចទាំងនេះជាបញ្ហា ច្បាប់ប្រកបដោយភាពស្មុគស្មាញ។ ប្រសិនណា អ.ប.ជ យល់ថាចាំបាច់ត្រូវពិចារណាលើរឿងរ៉ាវ បញ្ហាផ្សេងៗទៀត ដែលហួសពីវិសាលភាពនៃកថាខ័ណ្ឌទាំងដប់នេះ ហើយបង្គាប់ឱ្យមេធាវី ការពារក្ដីត្រូវឆ្លើយតប មេធាវីសូមគោរពស្នើសុំទៅតុលាការថា ដើម្បីផលប្រយោជន៍យុត្តិធម៌ មេធាវីការពារក្ដីគួរទទួលបានការអនុញ្ញាតឱ្យដាក់សារណាបន្ថែម។

## II. **សេចក្ដីថ្លែងពីអង្គហេតុពាក់ព័ន្ធ**

4. កាលពីខែសីហា ឆ្នាំ ១៩៧៩ លោក **អៀង សារី** ត្រូវបានជំនុំជម្រះនិងកាត់ឲ្យជាប់ទោស *កំបាំងមុខ* ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[10]។ សាលក្រមបានកាត់ទោសលោក **អៀង សារី** ប្រហារជីវិត និង រឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់។ លោក **អៀង សារី** មិនត្រូវបានឃុំខ្លួន នៅមុនពេល

---

[7] ច្បាប់ស្ដីពីការដាក់ក្រុម "កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់" ( ហៅថា "ច្បាប់ឆ្នាំ១៩៩៤") ។

[8] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ១៣ ។

[9] លោក អៀង សារី ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់បំផុតពូជ និង អំពើអមនុស្សធម៌ដទៃទៀត) និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ (មនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ការនិរទេស ឬ ការជន្លៀស ឬ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)" ។ សូមមើលដីកាបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌទី ១ ។ ក.ស.ច.ស បានលើកឡើងថាការចោទប្រកាន់ទាំងនេះ គឺ "មិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ" ។

[10] សាលក្រមរបស់តុលាការបដិវត្តប្រជាជន U.N. A/34/491, ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ១៩៧៩ ទំព័រ៤ [ហៅថាសាលក្រមរបស់តុលាការប្រជាជន] ។

កំឡុងពេល ឬ ក្រោយពេលសវនាការទេ ហេតុដូច្នេះ សាលក្រមនោះមិនត្រូវបានអនុវត្តឡើយ។

5. ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៤ រដ្ឋសភាកម្ពុជាបានប្រកាសឲ្យប្រើ **ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់**[11]។ នៅក្នុងចំណោមនោះ ច្បាប់នេះប្រកាសដាក់ក្រុម"កម្ពុជាប្រជាធិបតេយ្យ" និង កងកម្លាំងយោធារបស់ខ្លួនឲ្យនៅក្រៅច្បាប់ ហើយថា សមាជិកភាពរបស់ក្រុមនេះគឺខុសច្បាប់[12] ។

6. នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ១៩៩៦ ដោយមានសំណើពីសហនាយករដ្ឋមន្ត្រីទាំងពីរ ព្រះមហាក្សត្រទ្រង់បានអនុវត្តអំណាចស្របច្បាប់របស់ព្រះអង្គ ដែលអនុញ្ញាតដោយរដ្ឋធម្មនុញ្ញកម្ពុជា[13] ព្រះរាជទានការលើកលែងទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់លោក **អៀង សារី** តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តឆ្នាំ ១៩៧៩ និង ប្រទានការអនុគ្រោះទោសពីការចោទប្រកាន់ក្រោមច្បាប់ឆ្នាំ១៩៩៤ នោះ[14]។ ការអនុគ្រោះទោសនោះគឺជាថ្នូរនឹងការចុះ

---

[11] ច្បាប់ឆ្នាំ ១៩៩៤ ។

[12] មាត្រា ១ និង មាត្រា៤នៃច្បាប់ឆ្នាំ ១៩៩៤ ។

[13] មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស" ដែលព្រះអង្គតែងតែអនុវត្តសិទ្ធិនេះជាច្រើនលើកច្រើនដងនៅថ្ងៃចំរើនព្រះជន្មរបស់ព្រះអង្គ នៅថ្ងៃបុណ្យចូលឆ្នាំខ្មែរនាខែមេសា និងនៅពិធីគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រ ។ ឧ.ទ សូមមើលអត្ថបទរបស់ ASIAN POL.NEWS ក្រោមចំណងជើងថា ព្រះមហាក្សត្រថ្មីរបស់កម្ពុជាបន្ធូរបន្ថយទោសទណ្ឌិត៨៨នាក់ ។ ក្រោមច្បាប់កម្ពុជា ពុំមានការដាក់កម្រិតទៅលើកម្មវត្ថុនៃបទល្មើសដែលអាចបន្ធូរបន្ថយទោស ឬ លើកលែងទោសដោយព្រះមហាក្សត្រឡើយ។ឧ.ទ សូមមើលការលើកលែងទោសព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ពីបទផ្តួលរំលំរដ្ឋាភិបាល ។ *ព្រះមហាក្សត្រកម្ពុជាព្រះទានការលើកលែងទោសព្រះអង្គម្ចាស់ដែលនិរទេស* អត្ថបទរបស់ Agence France Press ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៩៨ ។

[14] ព្រះរាជក្រិត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ ។ ពាក្យ "ការលើកលែងទោស" (amnesty) អាចមានន័យថា "អនុគ្រោះទោស" (pardon) ដោយរដ្ឋាភិបាលដល់ក្រុម ឬ ថានៈរបស់មនុស្ស ជាទូទៅសំណៅទៅលើបទល្មើស នយោបាយដែលជាចំណាត់ការរបស់អំណាចបូរណភាពអត់អោនទោសផ្លូវការដល់ក្រុមមនុស្សជាក់លាក់ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តី ប៉ុន្តែមិនទាន់ផ្តន្ទាទោសនៅឡើយ" ។
BLACK'S LAW DICTIONARY 83 (7th ed) 1999. គោលបំណងដ៏ចំបងក្នុងការលើកលែងទោស គឺដើម្បីបង្កើតលក្ខខណ្ឌសម្រាប់ការផ្សះផ្សារ និងបញ្ចប់ជម្លោះ។ ការលើកលែងទោសត្រូវបានប្រើប្រាស់ជាញឹកញយជាបច្ចេកទេសដើម្បីបញ្ចប់សង្គ្រាម ឬ ដើម្បីជំរុញអន្តរភាពពីរដ្ឋាភិបាលផ្តាច់ការមករដ្ឋាភិបាលប្រជាធិបតេយ្យ ។ សូមមើលអត្ថបទរបស់ Mahnoush Arsanjani ក្រោមចំណាហជើងថា *តុលាការព្រហ្មទណ្ឌអន្តរជាតិ និង ច្បាប់លើកលែងទោសជាតិ,* 93 AM. SOC's INT'L L.PROC. 65 (1999) ។ សារប្រយោជន៍ របស់ពួកគេ ត្រូវបានកត់សំគាល់ដោយអ្នកប្រវត្តិវិទូជាច្រើន ។ ឧ.ទ សូមមើលអត្ថបទរបស់លោក William A. Schabas ក្រោមចំណងជើងថា *គណៈកម្មការស្វែងរកការពិត និង ផ្សះផ្សារជាតិ និងតុលាការពិសេសសៀរ៉ាឡេអូន,* 11 U.C. DAVIS J. INT'L L. & POL'Y, 145 165-68 (2004), ដែលបានថ្លែងថា "

ចូលរបស់លោក **អៀង សារី** ជាមួយរដ្ឋាភិបាលកម្ពុជា ដែលបាននាំទៅរកការបញ្ចប់ជម្លោះរវាងកងទ័ពរដ្ឋាភិបាលជាមួយកងយោធាដែលស្ថិតនៅក្រោមបញ្ជារបស់លោក **អៀង សារី**[15]។ សុពលភាពនៃការអនុគ្រោះទោសនេះមិនដែលចោទឡើងជាបញ្ហាឡើយ[16] ។

7. នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៩៧ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានស្នើសុំឲ្យលោកអគ្គលេខាធិការពិនិត្យសំណើសុំជំនួយរបស់អាជ្ញាធរកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការរំលោភយ៉ាងធ្ងន់ធ្ងរ ពីអតីតកាល លើច្បាប់កម្ពុជា និង ច្បាប់អន្តរជាតិ[17]។ មានការចរចាជាបន្តបន្ទាប់រវាងអង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា។ ជាចុងក្រោយ វាបានហុចលទ្ធផលឲ្យមានច្បាប់មួយដើម្បីបង្កើតតុលាការពិសេសមួយក្នុងប្រព័ន្ធតុលាការកម្ពុជា សម្រាប់កាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលត្រូវបាន

---

សន្តិភាព និង ការផ្សះផ្សារជាតិ ទាំងពីរមានតំលៃជានិត្យានុកូលភាពដែលគួរ តែមានកន្លែងរបស់ខ្លួននៅក្នុងច្បាប់សិទ្ធិមនុស្ស ។ ពួកគេត្រូវមានតុល្យភាពជាមួយនឹងសារភាពសំខាន់នៃការជំនុំជម្រះទោស ជាជាងការបោះបង់ចោលដោយងាយៗ" ។ លោក Schabas ក៏បានកត់សំគាល់នូវសេចក្ដីថ្លែងការណ៍របស់លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិទៅកាន់ក្រុមប្រឹក្សាសន្តិសុខថា ការបដិសេធនូវការលើកលែងទោសណាមួយចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋម្មប្រឆាំងមនុស្សជាតិ គឺជាការអកុសលមួយ ពីព្រោះការលើកលែងទោសអាចមានសារប្រយោជន៍ក្នុងការជំរុញសន្តិភាព ហើយចំណុចនេះវាបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៦(៥) នៃវិធីសារបន្ថែម II ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ វិធីសារបន្ថែម II ចែងថា "នៅពេលបញ្ចប់អរិភាព អាជ្ញាធរកាន់អំណាចត្រូវប្រឹងប្រែងជំរុញការលើកលែងទោសដល់បុគ្គលដែលបានចូលរួមក្នុងជម្លោះប្រដាប់អាវុធ ឬ ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាពដោយសារពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធ មិនថាពួកគេស្ថិតនៅក្រោមការបង្ខាំងទុក ឬ ឃុំខ្លួនឡើយ" ។

[15] សូមមើលអត្ថបទរបស់លោក Dominick Faulder ក្រោមចំណងជើងថា *បង្ហូរឈាមខ្មែរក្រហម (Bleeding the Khmer Rouge)* ASIA WEEK, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦, "ហ៊ុន សែន ប្រាប់ ASIA WEEK ថាការចាកចេញរបស់លោក **អៀង សារី** នឹងជំរុញឲ្យមានការផ្ដាច់ខ្លួនក្នុងទ្រង់ទ្រាយធំ និងកាត់បន្ថយកំលាំងរបស់ខ្មែរក្រហម ៨០% ។ ប៉ុន្តែល្បឿននៃការផ្ដាច់ខ្លួនមានចលនាលឿនជាងការទោះទាយរបស់លោក ហ៊ុន សែន ។ កាលពីសប្ដាហ៍កន្លងទៅ ទាហានខ្មែរក្រហមប្រាំបីកងពលដែលមានទាហាន ២៥០០នាក់ បានចុះចូលជាមួយភាគីរដ្ឋាភិបាល" ។

[16] សូមមើលកថាខណ្ឌទី ១១ ដល់ទី១៤ នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនបានចោទសួរនូវភាពស្របច្បាប់នៃការលើកលែងទោស ប៉ុន្តែវាអនុវត្តចំពោះឧក្រិដ្ឋកម្មដែលចោទជាបញ្ហានៅទីនេះ ។

[17] សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 52/135 ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា A/RES/52/135 ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ កថាខណ្ឌ ១៦ ។

បានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[18]។ ទីបំផុត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា "អ.វ.ត.ក.") បានចាប់ផ្ដើមប្រតិបត្តិការជាតុលាការក្នុងស្រុកមួយក្នុងប្រព័ន្ធតុលាការកម្ពុជា នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧[19]។

---

[18] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នស/រកម/០៨០១/១២ ។ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ។ សូមមើលច្បាប់វិសោធនកម្ម លេខសំគាល់ ៤៦ ខាងក្រោម ។

[19] សូមមើលរបាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្ដីពីការកាត់សេចក្ដីខ្មែរក្រហម លេខ A/57/769 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌទី ៣១ ដែលប្រកាសថា "អង្គជំនុំជម្រះវិសាមញ្ញ គឺជាតុលាការជាតិរបស់កម្ពុជាបង្កើតនៅក្នុងរចនាសម្ព័ន្ធតុលាការរបស់ប្រទេសកម្ពុជា" អនុលោមទៅតាមសេចក្ដីព្រាងច្បាប់ ។ នេះគឺជាគោលជំហររបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ។"ដោយប្រើប្រាស់ប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ហើយជ្រើសយកទីក្រុងភ្នំពេញជាទីកន្លែងសម្រាប់ដំណើរការនីតិវិធីដើម្បីការពារបូរណភាពនៃព្រះរាជាណាចក្រកម្ពុជា"។ (បញ្ជាក់បន្ថែម)។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ០៤០/០០២/២០០១ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ។ អនុលោមទៅតាមលោក David Boyle, មន្ត្រីច្បាប់នៅ ក.ស.ច.ស "សាលាក្ដីខ្មែរក្រហមគឺជាតុលាការផ្លូវការក្នុងតុលាការជាតិកម្ពុជា...មានកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការជំនុំជម្រះនេះ ប៉ុន្តែកិច្ចព្រមព្រៀងនោះ មិនបានបង្កើតតុលាការទេ ។ វាគ្រាន់តែរៀបចំឱ្យមានការចូលរួមពីអន្តរជាតិនៅក្នុងតុលាការនោះតែប៉ុណ្ណោះ ។ របាយការណ៍ថ្មីៗរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិយោងតុលាការនេះថាជាជំនួយបច្ចេកទេស" ។ បើផ្អែកលើលោក David Boyle ក្របខណ្ឌច្បាប់ របស់សាលាក្ដីខ្មែរក្រហមដែលលើកយកមកពិភាក្សានៅកម្មវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលរៀបចំដោយ FIDH-LICADHO-ADHOC ក្រោមវិធានបទៈ ភាពស្របគ្នារវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង សាលាក្ដីខ្មែរក្រហមៈ ទីកន្លែងរបស់ជនរងគ្រោះ ដែលប្រព្រឹត្តទៅចាប់ថ្ងៃទី២ ដល់ទី៣ ខែឧសភា ឆ្នាំ២០០៥ ។ អាចរកបាននៅគេហទំព័រ: http:www.vrwg.org/02/FIDHcambodge420ang.pdf ។ ចំណុចនេះក៏ត្រូវបានគូសបញ្ជាក់ដោយអង្គបុរេជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចលើកដំបូងរបស់ខ្លួន ។ អង្គបុរេជំនុំជម្រះបានលើកឡើងថា "សម្រាប់គោលបំណងអនុវត្ត ច្បាប់ និងប្រតិបត្តិការទាំងអស់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា" ករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ០១) ។ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌទី ១៩ ។ (បញ្ជាក់បន្ថែម)។ ទោះបីអង្គបុរេជំនុំជម្រះបានយោងទៅលើសេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាដែលបានសន្និដ្ឋានថា ដោយសារតែមានភាពឯករាជ្យនេះហើយ ទើបធ្វើឱ្យអង្គជំនុំជម្រះវិសាមញ្ញ "ក្លាយជាសាលាក្ដីដែលមានចរិតលក្ខណៈអន្តរជាតិពិសេស" ។ ពួកគេមិនបានជ្រើសយកដោយចេតនានូវសេចក្ដីថ្លែងការណ៍ដែលថា អ.វ.ត.ក មានចរិតលក្ខណៈជាអន្តរជាតិ។រាល់ការប៉ុនប៉ងណាមួយរបស់សហព្រះរាជអាជ្ញាដើម្បីប្រែក្លាយ អ.វ.ត.ក ឱ្យទៅតុលាការអន្តរជាតិ តាមរយៈការដាក់ឈ្មោះវាថាជា"តុលាការដែលមានចរិតលក្ខណៈអន្តរជាតិ" គឺផ្ទុយពីចេតនារបស់រដ្ឋាភិបាលកម្ពុជាក្នុងការបង្កើត អ.វ.ត.ក ជាផ្នែកមួយនិងជាកញ្ចប់នៃតុលាការកម្ពុជា ។ទោះបីអង្គការសហប្រជាជាតិផ្ដល់ជំនួយបច្ចេកទេសដល់សាលាក្ដី ក្រោមផ្លាកឈ្មោះជំនួយរបស់អង្គការសហប្រជាជាតិដល់សាលាក្ដីខ្មែរក្រហម ក៏មិនបានផ្លាស់ប្ដូរឋានៈរបស់ អ.វ.ត.ក ជាតុលាការជាតិដែរ ដែលបង្កប់យ៉ាងរឹងមាំនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ នៅក្នុងការបង្កើត អ.វ.ត.ក រដ្ឋាភិបាលកម្ពុជា មិនបានប្រគល់បូរណភាពលើប្រព័ន្ធតុលាការរបស់ខ្លួនមួយផ្នែកឬទាំងស្រុងទៅឱ្យអង្គការសហប្រជាជាតិ

8. នៅថ្ងៃទី ១៤ វិច្ឆិកា ឆ្នាំ ២០០៧ ក.ស.ច.ស. បានចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលោក **អៀង សារី** ។ នៅក្នុងដីកានេះ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន *propio motu* ក.ស.ច.ស. បានលើកឡើងអំពីបញ្ហាយុត្តាធិការ នៃ គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (***ne bis in idem)*** និង ប្រសិទ្ធិភាព នៃ ព្រះរាជក្រិត្យលើកលែងទោស ដោយមិនបានផ្ដល់ឱកាសឲ្យគូភាគីធ្វើសវនាការសាកសួរដេញដោលគ្នាលើបញ្ហានោះជាមុនឡើយ ។

## III. សេចក្ដីសង្ខេបនៃអង្គហេតុ

9. បណ្ដឹងឧទ្ធរណ៍នេះនឹងបង្ហាញឲ្យឃើញថា ក.ស.ច.ស. មានកំហុសនៅក្នុងការសម្រេចថា គោលការណ៍ ***ne bis in idem*** មិនអាចអនុវត្តបាន ពីព្រោះ៖

(១) គោលការណ៍នេះគ្មានអញ្ញត្រកម្ម (ការលើកលែង) នៅក្នុងច្បាប់កម្ពុជាទេ។ ក៏ប៉ុន្តែបើទោះជាគេសម្រេចថាអ.វ.ត.ក អាចលើកយកអញ្ញត្រកម្មនេះមកពិនិត្យចំពោះគោលការណ៍ *ne bis in idem* នេះយ៉ាងណាក្ដី ក៏អញ្ញត្រកម្មដូចដែលបានលើកឡើង (តែមិនបានផ្អែកទៅលើ) ដោយសហចៅក្រមស៊ើបអង្កេតនោះគឺមិនអាចអនុវត្តទៅលើរឿងក្ដីបច្ចុប្បន្ននេះបានឡើយ។

(២) ហេតុដែលថាលោក **អៀង សារី** មិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងរឿងក្ដីបច្ចុប្បន្ន ក៏មិនត្រូវធ្វើឲ្យទៅជាមោឃៈនូវភាពអាចអនុវត្តបាននៃគោលការណ៍ ***ne bis in idem*** ចំពោះករណីនេះឡើយ។ គោលការណ៍ ***ne bis in idem*** នេះត្រូវអនុវត្តដើម្បីរារាំងដល់ការជំនុំជម្រះជាថ្មី ដោយអាងថាអង្គហេតុទាំងនោះគឺដូចគ្នានឹងអង្គហេតុដែលមាននៅក្នុងសវនាការកាលពីលើកមុន។ វាមិនចោទជាបញ្ហាទេ ទោះជាឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នោះ មានកំណត់ឈ្មោះបទល្មើសផ្សេងៗទៅវិញក្ដី។

(៣) ទស្សនាទាននៃកាត់ទោសត្រួតគ្នានេះមិនអាចអនុវត្តបានទេ ចំពោះសវនាការជំនុំជម្រះពីរផ្សេងគ្នា ដែលមានគម្លាតពេលខុសពីគ្នាជិត ៣០ ឆ្នាំហើយនោះ។

(៤) ទស្សនាទាននេះក៏មិនអាចប្រើបានឡើយ ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវមានលាយឡំចូលគ្នាជាមួយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងករណីនេះរួចទៅហើយ ហើយជាចំណុចចុងក្រោយ

---

ឬអង្គការអន្តរជាតិណាមួយដែរ ។ សូមមើលឧបសម្ព័ន្ធ ក ដែលបង្ហាញថា អ.វ.ត.ក គឺមានលក្ខណៈជាតុលាការក្នុងស្រុកច្រើនជាងតុលាការកូនកាត់ ឬ តុលាការអន្តរជាតិ ។

(៥) តាមពិត សវនាការជំនុំជម្រះរឿងក្ដីនៅឆ្នាំ ១៩៧៩ នោះបានគ្របដណ្ដប់លើបទល្មើសទាំងអស់ដែលលោក **អៀង សារី** កំពុងរងការចោទប្រកាន់ នាពេលបច្ចុប្បន្ននេះ។

10. បណ្ដឹងឧទ្ធរណ៍នេះនឹងបង្ហាញបន្ថែមទៀតថា ប្រសិនណាគោលការណ៍ ***ne bis in idem*** ត្រូវបានយល់ឃើញថាមិនអាចអនុវត្តទៅលើរឿងក្ដីបច្ចុប្បន្ននេះទេ ក៏ ព្រះរាជក្រឹត្យលើកលែងទោសដែលផ្ដល់ឲ្យលោក **អៀង សារី** នៅតែរារាំងមិនឲ្យមានការកាត់ទោសលើរូបគាត់នាពេលបច្ចុប្បន្ននេះឡើយ ដោយសារតែ **ច្បាប់ឆ្នាំ ១៩៩៤** បានគ្របដណ្ដប់លើបទល្មើសទាំងអស់ ដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះរួចហើយ។

## IV. **ឧឡឹករណ៍**

### ក. ***គោលការណ៍ Ne bis in idem***[20]

11. គោលការណ៍ ***ne bis in idem*** ដែលទទួលស្គាល់ដោយ ក.ស.ច.ស. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន[21] រារាំងការចោទប្រកាន់ដោយតុលាការក្រោយៗមកទៀតសម្រាប់កាត់ក្ដីឯកត្តបុគ្គលណាមួយ ចំពោះបទល្មើស អង្គហេតុ ឬ បុព្វហេតុនៃអំពើ ដែលឯកត្តបុគ្គលនោះត្រូវបានកាត់ក្ដីឲ្យជាប់ទោសរួចហើយ[22] ឬ សម្រេចឲ្យរួចខ្លួនជាស្ថាពរហើយនោះ។ *Ne bis in idem* គឺជាគោលការណ៍គ្រឹះនៃច្បាប់សិទ្ធិមនុស្ស ហើយត្រូវបានទទួលស្គាល់ដោយលិខិតូបករណ៍អន្តរជាតិជាច្រើនអនេក[23] ព្រមទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ[24]។ កិច្ចព្រមព្រៀងបង្កើត

---

[20] ទ្រឹស្ដី *Ne bis in idem* ត្រូវបានស្គាល់ក្រោមរូបមន្តខុសៗគ្នាជាច្រើនមានដូចជា វិធានអាជ្ញាអស់ជំនុំ (res judicata), autrefois acquit (សម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ), autrefois convict (ផ្ដន្ទាទោសជាស្ថាពរហើយ) និង ការការពារប្រឆាំងនឹងការកាត់ទោសពីរដងក្នុងបទល្មើសតែមួយ double jeopardy ។ ពុំមានភាពខុសគ្នាជាដុំកំភួនទេរវាងរូបមន្តទាំងនេះ ។ សូមមើលករណី Christine Van den Wyangaert & Tom Ogena, *គោលការណ៍* Ne bis in idem *រួបបញ្ចូលទាំងបញ្ហាអនុ គ្រោះទោស* នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិៈ សេចក្ដីអធិប្បាយលេខ ៧០៥ at 706 (Antonio Cassese, Paola Gaeta, John R. W. D. Jones, eds).

[21] ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ ៧ ។

[22] ដូច ក.ស.ច.ស បានសង្កេត ទោះបីជាមានការផ្ដន្ទាទោសជាស្ថាពររួចហើយក៏ដោយ ក៏វាមិនចោទជាបញ្ហាដែរ ការអនុគ្រោះទោសលោក **អៀង សារី** ត្រូវកម្រិតមកត្រឹមការលុបចោលនូវទណ្ឌកម្មតែប៉ុណ្ណោះ "ការអនុគ្រោះនេះមិនប៉ះពាល់ដល់សាលក្រមផ្ដន្ទាទោសនោះទេ" ។ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ១២ ។

[23] ឧ.ទ សូមមើល មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា ៤ នៃអនុសញ្ញាស្ដីពីសិទ្ធិមនុស្សរបស់សហភាពអឺរ៉ុប មាត្រា ៧ នៃវិធីសារ មាត្រា ១០ នៃលក្ខន្តិកៈ ICTY និង មាត្រា ៩ នៃលក្ខន្តិកៈ ICTR ។

អ.វ.ត.ក បានចែងយ៉ាងច្បាស់ផងដែរថា "គ្មានជនណាម្នាក់ត្រូវបានកាត់សេចក្តី ឬ ផ្តន្ទាទោសសារជាថ្មីចំពោះបទល្មើសដែលត្រូវបានផ្តន្ទាទោសជាស្ថាពរ ឬ ត្រូវបានសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសនីមួយៗនោះឡើយ"[25] ។

12. ក.ស.ច.ស. បានសម្រេចថា "ជាវិធានទូទៅ លក្ខន្តិកៈ និង ការអនុវត្តរបស់សាលាក្តីអន្តរជាតិ និងតុលាការដែលមានចារីតលក្ខណៈជាអន្តរជាតិ អនុញ្ញាតឱ្យមានការជំនុំជម្រះទោសមនុស្សម្នាក់ចំពោះអំពើដដែល និង ក្រោមការកំណត់បទល្មើសដូចគ្នា[26]" ជាពិសេស កាលណាដំណើរការកាត់ក្តីកាលពីគ្រាមុននោះ ៖

(ក) មានគោលបំណងរារាំងជនពាក់ព័ន្ធឱ្យរួចផុតពីការទទួលខុសត្រូវលើបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ឬ

(ខ) មិនបានប្រព្រឹត្តទៅដោយឯករាជ្យ ឬ អនាគតិ ស្របតាមបទដ្ឋាននៃដំណើរការត្រឹមត្រូវ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ និង ត្រូវបានដំណើរការទៅតាមរបៀបនៅក្នុងកាលៈទេសៈ ដែលមិនស្របទៅនឹងឆន្ទៈក្នុងការនាំជនជាប់ពាក់ព័ន្ធនោះមកកាន់យុត្តិធម៌[27] ។

13. មេធាវីការពារសុំតុលាការពិចារណាថា សិទ្ធិមិនត្រូវជំនុំជម្រះជាថ្មីចំពោះបទល្មើសដដែល ត្រូវបានការពារដោយច្បាប់កម្ពុជា[28] ដែលឥតមានអញ្ញត្រកម្មឡើយ។ ឱ្យតែអញ្ញត្រកម្មដូចបានលើកឡើងដោយ ក.ស.ច.ស ពិតជាមានអត្ថិភាពនិងប្រើបាននៅចំពោះមុខ អ.វ.ត.ក មែន នោះមេធាវីការពារសុំអះអាងថា ទោះយ៉ាងណាក្តី អញ្ញត្រកម្មទាំងនោះមិនអាចអនុវត្តបានឡើយចំពោះរឿងក្តីបច្ចុប្បន្ននេះ។ ក.ស.ច.ស បានត្រឹមតែលើកឡើងអំពីអញ្ញត្រកម្មចំពោះគោលការណ៍ *ne bis in edem* នេះ ប៉ុន្តែមិនបានសម្រេចអំពីភាពអាចអនុវត្តបាននូវអញ្ញត្រកម្មទាំងនេះទៅលើករណីលោក

---

[24] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ (ហៅថា CPC) "ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។(បញ្ជាក់បន្ថែម) ។

[25] មាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ២០០៣ ចែងថា "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៣ និង ១៤ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី" ។

[26] កថាខណ្ឌទី ៨ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។

[27] ដូចខាងលើ ។

[28] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា រាយតារាបញ្ជីគ្មានអញ្ញត្រកម្មចំពោះគោលការណ៍នេះ ។ សូមមើលអត្ថបទមាត្រា ១២ និង លេខយោងទី ២៤ ។

អៀង សារី "ព្រោះថា ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការស៊ើបសួរបន្តរបស់តុលាការ អៀង សារី នាពេលនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍ឡើយ"[29] ។ យ៉ាងណាក្តី ដោយសារតែអញ្ញត្រកម្មទាំងនេះត្រូវបាននិទ្ទេសនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នហើយ នោះមេធាវីការពារនឹងលើកឡើងអំពីមូលហេតុដែលអញ្ញត្រកម្មទាំងនេះមិនអាចអនុវត្តបាន នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ។

14. អញ្ញត្រកម្មទីមួយ ចំពោះការអនុវត្តគោលការណ៍ *ne bis in edem* ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត មិនអនុវត្តចំពោះករណីបច្ចុប្បន្ននេះទេ។ អញ្ញត្រកម្មនេះអនុញ្ញាតឱ្យមានការជំនុំជម្រះទោសជាថ្មីបាន តែល្គឹកណាដំណើរការរឿងក្តីពីមុននោះត្រូវបានប្រព្រឹត្តឡើង "សម្រាប់គោលបំណងរារាំងជនពាក់ព័ន្ធឱ្យរួចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌប៉ុណ្ណោះ"[30]។ ដោយហេតុថាសវនាការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ នោះបានផ្តន្ទាទោសប្រហារជីវិតលោក អៀង សារី និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់[31] មេធាវីការពារសុំតុលាការមេត្តាពិចារណាថា សវនាការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ នោះ ប្រាកដជាមិនមានន័យចង់រារាំងលោក អៀង សារី ឱ្យរួចផុតពីទំនួលខុសត្រូវខាងព្រហ្មទណ្ឌឡើយ។ សម្រាប់មូលហេតុនេះ អញ្ញត្រកម្មទីមួយនេះមិនអាចអនុវត្តបានទេ។

15. ដូចគ្នានេះដែរ អញ្ញត្រកម្មទីពីរចំពោះការអនុវត្តគោលការណ៍ *ne bis in edem* ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ក៏មិនអាចអនុវត្តចំពោះរឿងក្តីបច្ចុប្បន្ននេះបានដែរ។ ម្យ៉ាងវិញទៀត អញ្ញត្រកម្មនេះនឹងអាចអនុវត្តបាន តែល្គឹកណាដំណើរការរឿងក្តីពីមុននោះ "មិនត្រូវបានប្រព្រឹត្តឡើងដោយឯករាជ្យ ឬ អនាគតិ ស្របតាមបទដ្ឋាននៃដំណើរការដោយត្រឹមត្រូវ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ និង ត្រូវបានដំណើរការទៅតាមរបៀប នៅក្នុងកាលៈទេសៈដែលមិនស្របទៅនឹងឆន្ទៈក្នុងការនាំជនជាប់ពាក់ព័ន្ធនោះមកកាន់យុត្តិធម៌[32]។ ជាក់ស្តែង សវនាការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ នោះ គ្មានបំណងជួយលោក អៀង សារី ឱ្យរួចផុតពីទោសកំហុសឡើយ ដោយហេតុថាគាត់ត្រូវបានផ្តន្ទាទោសប្រហារជីវិត និង ទ្រព្យសម្បត្តិទាំងអស់របស់គាត់ត្រូវបានបង្គាប់ឱ្យរឹបអូស[33] ។ សម្រាប់មូលហេតុនេះ អញ្ញត្រកម្មទីពីរនេះក៏មិនអាចអនុវត្តបានឡើយ។

---

[29] កថាខណ្ឌទី ៨ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។

[30] ដូចខាងលើ ។

[31] សាលក្រមរបស់តុលាការប្រជាជន ទំព័រទី៤ ។

[32] ដូចខាងលើ ។

[33] សាលក្រមរបស់តុលាការប្រជាជន ទំព័រទី៤ ។

16. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក.ស.ច.ស. បានលើកឡើងថា វាមិនចាំបាច់ត្រូវការពិចារណាថាតើអញ្ញត្រកម្មចំពោះគោលការណ៍ *ne bis in idem* អនុវត្តបានឬមិនបានយ៉ាងណានោះទេ ពីព្រោះបញ្ហានេះ "មិនចោទឡើងក្នុងពេលនេះឡើយ ព្រោះត្បិត ដោយមិនមានការប៉ះពាល់ដល់លទ្ធផលស៊ើបសួររបស់តុលាការដែលកំពុងដំណើរការ លោក **អៀង សារី** នាពេលនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍នោះទេ"[34]។ ទោះយ៉ាងណាក្តី សិទ្ធិមនុស្សជាមូលដ្ឋាន ដែលថាមិនត្រូវមានការកាត់ទោសទ្វេរដងនោះ មិនអាចបដិសេធចោលដោយងាយៗនោះទេ។ គោលការណ៍នេះ មិនមែនអនុវត្ត តែនៅពេលណាជនជាប់ចោទត្រូវរងការចោទប្រកាន់ពីបទឧក្រិដ្ឋដដែល ដែលអ្នកនោះត្រូវបានគេវិនិច្ឆ័យសេចក្តីពីមុនរួចមកហើយប៉ុណ្ណោះទេ។ ជាងនេះទៅទៀត គោលការណ៍នេះត្រូវបានប្រើជារនាំងដើម្បីឃាំងឃាត់មិនឲ្យមានការចោទប្រកាន់ទោសនៅពេលដែលជនជាប់ចោទបានទទួលសវនាការជំនុំជម្រះក្តីពីមុនរួចមកហើយ ចំពោះទង្វើល្មើសដដែល។ ប្រការនេះអាចត្រូវបានមើលឃើញយ៉ាងច្បាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា "នៅក្នុងការអនុវត្តគោលកាណ៏ **អាជ្ញាអស់ជំនុំនេះ** ជនទាំងឡាយណា ដែលត្រូវបានតុលាការកាត់សេចក្តីឲ្យរួចទោស
មិនអាចត្រូវបានចោទប្រកាន់ជាថ្មីម្តងទៀតចំពោះបទល្មើសដដែលបានទេ រួមទាំងរឿងក្តីដែលអំពើល្មើសមាននីតិចរិតលក្ខណៈផ្សេងក្តី[35]។ នេះជាចំនុចប្រត្យក្សជាក់ស្តែងស្មើគ្នានៅក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ អតីតយូហ្គោស្លាវី (ICTY) និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR)[36] ។

17. បន្ទាប់ពីការលើកឡើងថា គោលការណ៍ *ne bis in idem* មិនអាចអនុវត្តបាន ដោយហេតុថាលោក **អៀង សារី** មិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះ ក.ស.ច.ស នៅបានបន្តយល់ឃើញទៀតថា "គ្មានឧបសគ្គឃាំងឃាត់ការចោទប្រកាន់ទោស **អៀង សារី** ទេ

---

[34] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ ៨ ។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១២ (ត្រូវបានបញ្ជាក់បន្ថែម) ។

[36] មាត្រា ២០.១ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងថា "លើកលែងតែមានចែងនៅក្នុងលក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសនៅចំពោះមុខតុលាការចំពោះអំពើដែលបង្កបានជាបទល្មើស ដែលតុលាការបានកាត់សេចក្តីឲ្យជននោះជាប់ទោស ឬ ឲ្យរួចទោសនោះទេ"។ មាត្រា ១០.១ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីចែងថា "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសនៅចំពោះមុខតុលាការជាតិមួយចំពោះអំពើទាំងឡាយ ដែលត្រូវបានកាត់សេចក្តីដោយតុលាការ អន្តរជាតិបានទេ"។ (ត្រូវបានបញ្ជាក់បន្ថែម)។ សូមមើលមាត្រា ៩ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាផងដែរ។

ចំពោះអំពើទាំងឡាយដែលត្រូវបានគ្របដណ្ដប់ដោយសាលក្រមឆ្នាំ ១៩៧៩ ក្រោមច្បាប់អន្តរជាតិមួយ ក្រៅពីបទល្មើសប្រល័យពូជសាសន៍នោះ” ព្រោះតុលាការអន្តរជាតិបានអនុញ្ញាតឲ្យមានការកាត់ទោសត្រួតគ្នា គិតចាប់ពីពេលសវនាការក្តីនៅ Nuremburg[37]។ ទោះបីមិនបាច់គិតដល់ហេតុដែលថា អ.វ.ត.ក. ជាតុលាការជាតិក្នុងប្រទេសកម្ពុជាដែលត្រូវអនុវត្តច្បាប់កម្ពុជា[38] ហើយថាវាមិនមែនជាសាលាក្តីអន្តរជាតិក្តី ក៏ទស្សនាទានការកាត់ទោសត្រួតគ្នានេះមិនអាចអនុវត្តនៅទីនេះបានដែរ ពីព្រោះការកាត់ទោសបែបនេះត្រូវបានប្រើដោយសាលាក្តីអន្តរជាតិតែប៉ុណ្ណោះ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ត្រួតគ្នានៅក្នុងសវនាការដូចគ្នា[39]។ ក្នុងរឿងក្តីសព្វថ្ងៃ សវនាការទាំងពីរនេះត្រូវបានញែកដាច់ពីគ្នាអស់រយៈពេលជិត ៣០ ឆ្នាំទៅហើយ។

18. បើទោះបីជាទស្សនាទាននៃការកាត់ទោសត្រួតគ្នាត្រូវអនុវត្តនៅទីនេះក្តី ក៏ ក.ស.ច.ស គួរបានគិតពិចារណាពីលក្ខណៈវិនិច្ឆ័យសម្រាប់អនុញ្ញាតឲ្យមានការផ្តន្ទាទោសត្រួតគ្នានេះឲ្យបានល្អិតល្អន់មែនទែនសិន។ កន្លងមក យ៉ាងហោចណាស់ក៏មានការធ្វើតេស្តពិសោធន៍សំខាន់ៗចំនួនប្រាំ ដែលត្រូវបានប្រើប្រាស់ដោយសាលាក្តីអន្តរជាតិ និងតុលាការជាតិ ដើម្បីសម្រេចថាតើការផ្តន្ទាទោសត្រួតគ្នានឹងត្រូវបានអនុញ្ញាតដែរឬទេ[40] ហើយថាតើការធ្វើតេស្តមួយចំនួនក្នុងចំណោមការធ្វើ

---

37 ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ ៩ ។

38 មាត្រា ១២(១) នៃកិច្ចព្រមព្រៀងចែងថា “នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របរវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាច ស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”។ សូមមើល Göran Sluiter ដំណើរការត្រឹមត្រូវតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា ៤ J ។ យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (INT’L CRIME JUST) ៣១៤ ៣១៨-២២ (២០០៦)។

39 សូមមើល Hong S. Wills ការផ្តន្ទាទោសត្រួតគ្នា និងវិធានស្តីពីការកាត់ទោសទ្វេដងចំពោះបទល្មើសតែមួយៈ ការស្វែងរកយុត្តិធម៌នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា ១៧ EMORY INT’L L. REV. ៣៤១ ៣៧៦ (២០០៣) “ការផ្តោតការយកចិត្តទុកដាក់លើ[ការកាត់ទោសទ្វេដងចំពោះបទល្មើសតែមួយ] គឺចិតនៅលើការអនុញ្ញាតឲ្យមានការចោទប្រកាន់ជាបន្តបន្ទាប់ចំពោះបទល្មើសតែមួយ ជាជាងការផ្តន្ទាទោសត្រួតគ្នានៅក្នុងដំណើរ ការនីតិវិធីតែមួយ”។ *សូមមើល* Anne Bowen Poulin *ការកាត់ទោសទ្វេដងចំពោះបទល្មើសតែមួយ និងការផ្តន្ទាទោសច្រើនដងៈ* Cutting the Jordian Knot ៧៧ U. COLO.L.REV. 595 (២០០៦) ដែលពិភាក្សា (នៅក្នុងច្បាប់យុត្តិសាស្ត្រសហរដ្ឋអាមេរិក) បញ្ហានៃការភាន់ច្រលំគោលការណ៍នៃការកាត់ទោសទ្វេដងចំពោះបទល្មើសតែមួយ ជាមួយនឹងបញ្ហានៃការផ្តន្ទាទោសត្រួតគ្នា។

40 ការធ្វើតេស្តនេះរួមមាន “ធាតុផ្សំផ្សេងៗគ្នានៃ Akayesu ឬ ការធ្វើតេស្តដ៏គួរឲ្យចាប់អារម្មណ៍” “ចំនួនសរុបនៃការធ្វើតេស្តលើទង្វើទទួលខុសត្រូវ Tadić” “Kupreškić Blockbuger និងការធ្វើតេស្តតំលៃផ្សេងៗ” “Čelebići Two Prong

តេស្តទាំងនេះអាចរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទឬយ៉ាងណា[41]។ ក.ស.ច.ស ជាក់ស្តែង មិនបានពិភាក្សាពីរបៀបដែលខ្លួនគួរជ្រើសរើសរវាងពិសោធន៍ល្បងផ្សេងៗ ដើម្បីសម្រេចយករបៀបមួយណាដែលត្រូវអនុវត្តតាម និង មិនបានលើកឡើងឲ្យចំៗពីពិសោធន៍ល្បង ដែលខ្លួនបានយកមកអនុវត្តនៅក្នុងសេចក្តីសម្រេចរបស់ខ្លួននោះ។ ក.ស.ច.សគ្រាន់តែបានលើកឡើងថា ការផ្តន្ទាទោសត្រួតគ្នាអាចធ្វើទៅបានឲ្យតែ "បទល្មើសអន្តរជាតិនីមួយៗមានធាតុផ្សំផ្សេងដោយឡែកមួយ ដែលមិនមាននៅក្នុងបទល្មើសដទៃផ្សេងទៀត ហើយការពារតម្លៃផ្សេងៗគ្នា"[42]។

19. សុំអង្គតុលាការមេត្តាពិចារណាថា ធាតុផ្សំជាសារវន្តមួយ មានលក្ខណៈខុសស្រឡះពីធាតុផ្សំមួយផ្សេងទៀត ប្រសិនបើវាតម្រូវឲ្យមានភស្តុតាងនៃអង្គហេតុមួយ ដែលធាតុផ្សំផ្សេងទៀតនោះមិនតម្រូវឲ្យមាន[43]។ យ៉ាងណាក្តី ក.ស.ច.ស មិនបានបញ្ជាក់ថា ធាតុផ្សំនៃបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម ខុសគ្នាជាសារវន្តយ៉ាងណាឡើយ[44]។

---

Materially Distinct Element Test" និង "Judges Hunt និង Bennouna's Substative Sistinct Element Test "។ សូមមើល Wills សូមមើលកំណត់ចំណាំលេខ ៣៩ ខាងលើ។ វាមិនច្បាស់លាស់ថាតើការធ្វើតេស្តមួយណាដែល ក.ស.ច.ស អាចយកមកប្រើប្រាស់ ដោយសារថា Čelebići, Kupreškić និង Akayesu ត្រូវបានលើកឡើងនៅក្នុងលេខយោងកថាខណ្ឌ ៩ នៃដីកាសម្រេចឃុំ ខ្លួនបណ្តោះអាសន្ន។

[41] Wills កំណត់ចំណាំលេខ ៣៩ ខាងលើ ។

[42] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៩ ។

[43] រដ្ឋអាជ្ញា តទល់នឹង Delalić និងទាំងអស់ IT-៩៦-២១-A ។ សាលដីកាចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១២ [សាល ដីកា Čelebići]

[44] នៅក្នុងកថាខណ្ឌ ៩ នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក.ស.ច.ស បានពន្យល់យ៉ាងសាមញ្ញថា "វាត្រូវបានគេទទួលយកដោយ ថាជនម្នាក់អាចត្រូវបានចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម អាស្រ័យលើអំពើដូចគ្នា" និងថា "នៅក្នុងការអនុវត្តគោលការណ៍ទាំងនេះ វាហាក់ដូចជាពុំមានឧបសគ្គដល់ការចោទប្រកាន់ **អៀង សារី** ចំពោះអំពើដែលគ្របដណ្តប់សាលក្រមឆ្នាំ១៩៧៩ នៅក្រោមការកំណត់របស់ច្បាប់អន្តរជាតិ ក្រៅពីបទល្មើសប្រល័យពូជសាសន៍"។ ការប្រញាប់ប្រញាល់ និងការពិនិត្យលើបញ្ហាដ៏ស្មុគ្រស្មាញមិនបានគ្រប់គ្រាន់បែបនេះ បានធ្វើឲ្យមេធាវីការពារស្ថិតនៅក្នុងជំហរដ៏ ពិបាកក្នុងការប្តឹងជំទាស់ទៅនឹងផ្នែកណាមួយនៃសេចក្តីសម្រេច នៅពេលដែលហេតុផលដែលបានលើកឡើងដោយ ក.ស.ច.ស មានលក្ខណៈមិនគ្រប់គ្រាន់នោះ។ មេធាវីការពារដឹងថាវិសាលភាពនៃភារៈកិច្ចក្នុងការផ្តល់ហេតុផលប្រែប្រួលអាស្រ័យទៅលើសារៈសំខាន់នៃទឡ្ហីករណ៍ដែលបានលើកឡើង និងថាមិនមានទឡ្ហីករណ៍ណាមួយ និងគ្រប់ទឡ្ហីករណ៍ដែលបានលើកឡើងដោយ ភាគីក្តីមួយក្នុងចំណោមភាគីក្តីជាច្រើន ត្រូវបានលើកឡើងឲ្យបានលំអិតដូចគ្នានោះទេ ប៉ុន្តែនៅពេលចៅក្រម ឬអង្គបុរេជំនុំជម្រះ មានគំនិតផ្តួចផ្តើមលើកឡើងពីបញ្ហាបែបនេះ ដោយមិនមានការជូនដំណឹងជាមុនចំពោះសេចក្តីសន្និដ្ឋានដែលចេញដោយអង្គបុរេជំនុំ ជម្រះ ដែលជាការសំខាន់បំផុតនោះ។

20. ខណៈដែលទស្សនៈទាននៃការកាត់ទោសត្រួតគ្នាមិនអាចអនុវត្តបាននៅទីនេះ មេធាវីការពារក្ដីសូមលើកឡើងថា បទល្មើសប្រឆាំងនឹងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម<u>មិនតម្រូវ</u>ឲ្យបង្ហាញធាតុផ្សំណាមួយដែលបទល្មើសប្រល័យពូជសាសន៍មិនតម្រូវនោះទេ[45]។ ផ្ទុយទៅវិញ បទល្មើសប្រល័យពូជសាសន៍ប្រាកដជា<u>តម្រូវ</u>ឲ្យមានការបង្ហាញពីចេតនាជាក់លាក់ ដែលមិនមាននៅក្នុងលក្ខខណ្ឌនៃបទល្មើសដទៃៗផ្សេងទៀត[46]។ ហេតុនេះ មានតែការកាត់ទោសតាមបទប្បញ្ញត្តិជាក់

---

[45] សូមមើល ឧបសម្ព័ន្ធ ខ ដែលបានដាក់ភ្ជាប់មកជាមួយ ដែលរៀបរាប់ធាតុផ្សំដាច់ដោយឡែកពីគ្នាចំពោះអំពើជាមូលដ្ឋាននៃបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងនឹងមុំនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម និងបទល្មើសផ្សេងៗនៅក្រោមច្បាប់កម្ពុជា។ ដូចដែលបានឃើញនៅក្នុងតារាង ការបង្ហាញ*ធាតុចេតនា និងធាតុផ្សំនៃអំពើទាំងអស់*នៃបទល្មើសប្រឆាំងនឹងមុំនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម និងបទល្មើសថ្នាក់ជាតិរបស់កម្ពុជា ក៏ចាំបាច់ផងដែរសម្រាប់បទល្មើសប្រល័យពូជសាសន៍។ ផ្ទុយទៅវិញ អំពើ នីមួយៗ ដូចជា បទល្មើសប្រល័យពូជសាសន៍តម្រូវឲ្យមានការបង្ហាញពីធាតុចេតនាជាក់លាក់បន្ថែមទៀត។ ក្នុងករណីនេះ បទឧក្រិដ្ឋប្រល័យពូជសាសន៍រាប់បញ្ចូលគ្រប់ប្រភេទទាំងអស់នៃបទល្មើសផ្សេងៗ ដោយសារថា វាជាបទល្មើសជាក់លាក់បំផុត។ ធាតុផ្សំនៃបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងនឹងមុំនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម គឺកើតចេញពីធាតុផ្សំនៃបទល្មើស ICC ។ សូមមើល <u>http://www.icc-cpi.int/library/about/officialjournal/Element_of_Crimes_English.pdf</u>។ បទល្មើសដែលអាចផ្ដន្ទាទោសនៅក្រោមច្បាប់កម្ពុជាបាន កើតចេញពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ តារាងប្រៀបធៀបអំពើជាមូលដ្ឋាន នៃមនុស្សឃាត ទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញ ការប្រព្រឹត្តដោយឃោរឃៅ ការនិរទេស ការដាក់ ពន្ធនាគារ និងទាសភាព។ នៅក្នុងយុត្តិសាស្ត្ររបស់ ICTY អំពើប្រល័យពូជសាសន៍គឺជា "ការបង្កឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញារបស់សមាជិកនៃក្រុម" ដែលត្រូវបានបកស្រាយយ៉ាងទូលំទូលាយ។ "នៅក្នុងចំណោមបញ្ហាដទៃ ទៀត វាត្រូវបានគេយល់ថា <u>ជាអំពើធ្វើទារុណកម្ម ការប្រព្រឹត្តដោយអមនុស្សធម៌ និងបន្ទាបបន្ថោក អំពើហិង្សាផ្លូវភេទ រួមទាំង ការរំលោភសេពសន្ថវៈ</u> ការសួរចម្លើយដោយមានការវាយដំ ការគំរាមកំហែងដល់អាយុជីវិត និងការធ្វើឲ្យឈឺចាប់ដែលធ្វើឲ្យអន្តរាយដល់សុខភាព ឬបណ្ដាលឲ្យខូចទ្រង់ទ្រាយ ឬធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់សមាជិកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ។ ការឈឺចាប់ដែលបានបង្កឡើងនេះមិនចាំបាច់ត្រូវតែជាអចិន្ត្រៃយ៍ និងមិនចាំបាច់មិនអាចកែបាននោះទេ តែត្រូវតែធ្ងន់ធ្ងរ"។ រដ្ឋអាជ្ញា តទល់នឹង *Brđanin,* IT-99-36-T សាលក្រមចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខ័ណ្ឌ៦៩០ (<u>បានបន្ថែមសេចក្ដីបញ្ជាក់</u>)។ "<u>ការប្រព្រឹត្តដោយអមនុស្សធម៌...និងការនិរទេសខ្លួន</u> គឺឋិតនៅក្នុងចំណោមអំពើដែលអាចបង្កឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញា"។ រដ្ឋអាជ្ញា តទល់នឹង *Krstić,* IT-98-33-T សាលក្រមចុះថ្ងៃទី12 ខែសីហា ឆ្នាំ២០០១ កថាខ័ណ្ឌ៥១៣ (<u>បានបន្ថែមសេចក្ដីបញ្ជាក់</u>)។ ដូច្នេះហើយ បទល្មើសជាច្រើនត្រូវបានដាក់បញ្ចូលនៅក្នុងប្រភេទនេះ។ ទាក់ទងទៅនឹងបទឧក្រិដ្ឋសង្គ្រាមក្នុងការបដិសេធសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ នេះជាអំពើមួយក្នុងចំណោម អំពើដែលបានកំណត់ដែលអាចផ្ដន្ទាទោសបានដូចការធ្វើទុក្ខបុកម្នេញដែរ ព្រោះបទល្មើសប្រឆាំងនឹងមនុស្សជាតិ បង្កបានជា ការបដិសេធសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានរាប់បញ្ចូលថាជាធាតុដំបូងនៃការធ្វើទុក្ខបុកម្នេញ ដូចបទល្មើសប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៧(១)(ជ)នៃលក្ខន្តិកៈ ICC ។

[46] មាត្រា៤ នៃច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានការធ្វើវិសោធនកម្មដែលប្រកាសឲ្យប្រើកាលពីថ្ងៃទី២៤ ខែតុលា

លាក់ប៉ុណ្ណោះ គឺឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទើបអាចត្រូវលើកយកមកគិតគូនៅពេលធ្វើការពិចារណាពីគោលការណ៍នៃការកាត់ទោសត្រួតគ្នា[47]។

21. បទល្មើសដែលមានលក្ខណៈជាក់លាក់ច្រើន រួមបញ្ចូលទាំងបទល្មើសដែលមិនសូវជាក់លាក់នៅក្នុងនោះ ពីព្រោះការប្រព្រឹត្តបទល្មើសជាក់លាក់នោះច្បាស់ជាជួយបង្ហាញឱ្យឃើញពីការប្រព្រឹត្តបទល្មើសមិនសូវជាក់លាក់នោះ[48]។ ហេតុដូច្នេះ បទល្មើសប្រឆាំងមនុស្សជាតិមានរួមបញ្ចូលទៅក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍[49]។ ហេតុនេះហើយ ទើបវាសមហេតុសមផលណាស់ដែលត្រូវប្រកាន់ថា ការកាត់ទោសដំបូងពីបទឧក្រិដ្ឋប្រល័យពូជសាសន៍របស់លោក **អៀង សារី** ក្នុងឆ្នាំ ១៩៧៩ បានការពារគាត់មិនឱ្យមានការចោទប្រកាន់ទោសនាពេលក្រោយៗមកទៀតពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាមនៅលើមូលដ្ឋានអង្គហេតុដូចគ្នា។ លើសពីនេះទៀត ក.ស.ព បានចោទប្រកាន់ថាលោក **អៀង សារី** ត្រូវទទួលខុសត្រូវលើបទឧក្រិដ្ឋផ្សេងៗទៀត តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ ក.ស.ច.ស <u>មិនបាននិទ្ទេស</u>នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នថា ធាតុផ្សំជាក់លាក់ណាខ្លះដែលខ្លួនអះអាងមានរួមបញ្ចូលនៅក្នុងបទល្មើសផ្សេងៗនោះដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍។ និយាយឱ្យងាយស្តាប់ គឺ ក.ស.ច.ស មិនបានធ្វើការវិភាគអ្វីសោះ។

---

ឆ្នាំ២០០៤ [ចាប់ពីពេលនេះតទៅហៅថា ច្បាប់បង្កើត អ.វ.ត.ក] តម្រូវឱ្យបង្ហាញពី "គោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃ ក្រុមជាតិ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា"។ ផ្ទុយទៅវិញ មាត្រា៥ និងមាត្រា៦ ដែលកំណត់ពីធាតុផ្សំនៃបទល្មើសសម្រាប់ បទល្មើសប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម គ្រាន់តែតម្រូវថា បទល្មើសដែល"បានប្រព្រឹត្ត" ដោយមិនតម្រូវឱ្យមាន គោលបំណងជាក់លាក់នោះឡើយ។ គោលបំណងជាក់លាក់នេះហើយដែលបានលើកឡើងប្រកបដោយការស៊ីសង្វាក់គ្នាដើម្បី កំណត់បទល្មើសប្រល័យពូជសាសន៍ដាច់ពីបទល្មើសដទៃទៀត។ សូមមើល រដ្ឋអាជ្ញា តទល់នឹង *Kayishema & Ruzindana,* ICTR-95-1-T សាលក្រមចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខ័ណ្ឌ៩១ ដែលលើកឡើងថា " ចំនុចខុសគ្នាបទល្មើសប្រល័យ ពូជសាសន៍គឺគោលបំណងជាក់លាក់ (*dolus specialis*) ដើម្បីបំផ្លិចបំផ្លាញក្រុមមួយទាំងមូល ឬមួយផ្នែក"។

47 សាលដីកា *Čelebići* កថាខ័ណ្ឌ ៤១៣ ។

48 រដ្ឋអាជ្ញា តទល់នឹង *Krstić*, IT-98-33-A សាលក្រមចុះថ្ងៃទី១៩ ខែមេសាឆ្នាំ២០០៤ កថាខ័ណ្ឌ២១៨ ។

49 សូមមើល *Kayishema & Ruzindana,* ICTR-95-1-T សាលក្រមចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ កថាខ័ណ្ឌ៦៤៨ ដែលអង្គ ជំនុំជម្រះសាលាដំបូងបានលើកឡើងថា មនុស្សឃាតដោយចេតនា និងការសម្លាប់បំផុតពូជ គឺជាបទល្មើសប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបាន"ដាក់បញ្ចូលយ៉ាងពេញលេញនូវការចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍។

22. ការពិចារណាមួយផ្សេងទៀតដែល ក.ស.ច.ស បានប្រើប្រាស់នៅក្នុងការសម្រេចអនុញ្ញាតឱ្យមានកាត់ទោសត្រួតគ្នា គឺថាតើបទល្មើសផ្សេងៗគ្នាការពារតម្លៃផ្សេងៗដែរឬយ៉ាងណា[50]។ ការពិចារណានេះគួរភ្ជាប់ជាមួយនឹងតេស្តលើធាតុផ្សំខុសគ្នាជាសារវន្ត ដែលក្នុងនោះបទឧក្រិដ្ឋនីមួយៗមិនត្រឹមតែមានធាតុផ្សំខុសគេមួយៗនោះទេ ប៉ុន្តែគេក៏ត្រូវតែរកឱ្យឃើញថាបទល្មើសនីមួយៗនោះក៏ការពារលើតម្លៃផ្សេងៗគ្នាផងដែរ[51]។ ក.ស.ច.ស <u>មិនបាន</u>ពន្យល់ថាអ្វីជាតម្លៃជាក់លាក់ដែលបទល្មើសនីមួយៗបានការពារនិងថាហេតុអ្វីបានជាតម្លៃផ្សេងៗទាំងនោះខុសគ្នានោះទេ។ ក.ស.ច.ស គ្រាន់តែបានលើកឡើងថា "នៅក្នុងការអនុវត្តគោលការណ៍ទាំងនេះ តាមការកំណត់នៃច្បាប់អន្តរជាតិ វាហាក់ដូចជាពុំមានការរារាំងដល់ការចោទប្រកាន់ទោស **អៀង សារី** ចំពោះអំពើដែលបានគ្របដណ្តប់ដោយសាលក្រមឆ្នាំ១៩៧៩ ដែលហួសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះទេ[52]។

23. លើសពីនេះទៅទៀត សំណុំរឿងទាំងឡាយដែល ក.ស.ច.ស.[53] បានទាញជាសំអាង ហាក់ដូចជាជាបង្ហាញពីការអនុញ្ញាតឱ្យមានការកាត់ទោសត្រួតគ្នា ដោយសារតែការបើកសវនាការលើករណីទាំងនោះមិនបានធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ជនជាប់ចោទឡើយ ដោយហេតុថាការចោទប្រកាន់ជនជាប់ចោទលើទម្រង់នៃការទទួលខុសត្រូវពីរតំណាលគ្នា មិនចាំបាច់តម្រូវឱ្យមានសវនាការមួយថ្មីទាំងស្រុងនោះទេ។ រឿងក្តីមួយដែល ក.ស.ច.ស បានយោងសំដៅនោះគឺករណី *Čelibići*។ ការផ្តល់សំអាងហេតុផលចម្បងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃICTY ទៅលើបញ្ហាការកាត់ទោសត្រួតគ្នានៅក្នុងសាលដីការបស់ *Čelibići* នោះគឺបានពឹងផ្អែកទៅលើ"ហេតុផលនៃភាពយុត្តិធម៌ចំពោះជនជាប់ចោទ[54]។ ហេតុដូច្នេះ ការពិចារណាដូចគ្នាលើភាពយុត្តិធម៌ចំពោះលោក **អៀង សារី** គឺជាការចាំបាច់ដើម្បីការពារកុំឱ្យមានការកាត់ទោស ដោយផ្អែកលើអំពើដូចគ្នានៅក្នុងសវនាការពីរដាច់ដោយឡែកពីគ្នាអស់រយៈពេលជិត ៣០ ឆ្នាំមកហើយ។

24. តាមការពិភាក្សាលើគោលការណ៍ *ne bis in idem* របស់ខ្លួន ក.ស.ច.ស ទីបំផុត បានអះអាងថា "វាហាក់បីដូចជាច្បាស់ហើយថា សាលក្រមឆ្នាំ ១៩៧៩ នោះ មិនបានគ្របដណ្តប់លើអំពើទាំងអស់

---

[50] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ ៨ ។

[51] សូមមើល រដ្ឋអាជ្ញា តទល់នឹង *Kupreškić et al.*, IT-95-16-T សាលក្រមចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខ័ណ្ឌ ៦៩៥។

[52] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ ៩។

[53] ចំនុចនេះអនុវត្តចំពោះគ្រប់រឿងក្តីទាំងអស់ដែលបានលើកឡើងដោយ ក.ស.ច.ស នៅក្នុងលេខសំគាល់ ៣ និង ៤ នៃ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

[54] សាលដីកា *Čelibići* កថាខ័ណ្ឌ ៤១២ ។

ដែល **អៀង សារី** កំពុងរងការចោទប្រកាន់សព្វថ្ងៃនេះទេ[55]។ យ៉ាងណាក្តី តាមការទទួលស្គាល់ដោយខ្លួនឯងរបស់ក.ស.ច.សនេះ បង្ហាញឱ្យឃើញថា មិនមានការវិភាគដល់ទីជម្រៅត្រូវបានធ្វើឡើងទៅលើសវនាការជំនុំជម្រះក្តីនៅ ឆ្នាំ១៩៧៩នោះទេ នៅពេលពិចារណាចេញដីកាឃុំខ្លួនបណ្តោះអាសន្ននោះដោយគ្រាន់តែអះអាងថា "សហចៅក្រមស៊ើបអង្កេតនឹងសម្រេចនៅពេលក្រោយ ថាតើចាំបាច់ត្រូវធ្វើការវិភាគមួយឱ្យបានស៊ីជម្រៅពីសវនាការជំនុំជម្រះក្តីនោះ ដែលរៀបចំឡើង [sic] ដោយតុលាការបដិវត្តន៍ប្រជាជនក្នុងឆ្នាំ ១៩៧៩[56]ឬយ៉ាងណានោះ។ គ្មានព័ត៌មាន ឬយុត្តិកម្មណាមួយត្រូវបានផ្តល់ឱ្យស្តីពីរបៀប និងពីហេតុដែលការអះអាងបែបនោះត្រូវបានបង្កើតឡើងឡើយ ឬ វាក៏មិនត្រូវបានគាំទ្រដោយការពន្យល់ណាមួយពី ក.ស.ច.ស. ថាផ្នែកណាមួយពិតប្រាកដនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនត្រូវបានគ្របដណ្តប់ដោយសវនាការជំនុំជម្រះក្តីឆ្នាំ ១៩៧៩ នោះ។

25. មូលដ្ឋានអង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះឆ្នាំ ១៩៧៩ គ្របដណ្តប់លើបទល្មើសដែលបានចោទប្រកាន់ទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សម្រាប់ការវិភាគប្រៀបសូមមើល ឧបសម្ព័ន្ធ គ ដែលមានភ្ជាប់មកជាមួយនេះ[57]។

## ខ. ព្រះរាជទានលើកលែងទោសនិងអនុគ្រោះទោស

26. ក.ស.ច.ស មិនបានចោទសួរពីនីត្យានុកូលភាពនៃ **ព្រះរាជក្រឹត្យលើកលែងទោស** ជូនចំពោះលោក **អៀង សារី** ក្នុងឆ្នាំ ១៩៧៩ នោះទេ។ លើសពីនេះទៅទៀត ក.ស.ច.ស មិនបានបង្ហាញឱ្យឃើញថា **ព្រះរាជក្រឹត្យលើកលែងទោស** ដែលចេញដោយព្រះមហាក្សត្រ ដោយអនុលោមតាមអំណាចរដ្ឋធម្មនុញ្ញរបស់ព្រះអង្គ មុនការចាប់បដិសន្ធិ ឬ ការបង្កើត អ.វ.ត.ក ជាលិខិតុបករណ៍ច្បាប់ដែលមិនភ្ជាប់កាតព្វកិច្ចឱ្យអ.វ.ត.កត្រូវតែអនុវត្តនោះឡើយ។ ទាំងការអនុគ្រោះទោស ទាំងការលើកលែងទោសត្រូវបានផ្តល់ឱ្យដោយអនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា[58]។ ក.ស.ច.ស

---

[55] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ ១០ ។

[56] ដូចគ្នានឹង កថាខ័ណ្ឌ ៨ ។

[57] មេធាវីការពារក្តីសូមដាក់ជូនតារាងដែលជាឧបសម្ព័ន្ធសម្ងាត់ទៅនឹងសារណាទាំងនេះ ដោយហេតុថាខ្លឹមសារនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរជាការសម្ងាត់។ ដើម្បីអនុញ្ញាតឱ្យសារណាទាំងនេះទៅជាសាធារណៈ មេធាវីការពារពឹងពាក់ទៅលើសេចក្តីសម្រេចជា សាធារណៈ ដូចជា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ដូច្នេះ មានតែឧបសម្ព័ន្ធនេះទេដែលជាការសម្ងាត់។

[58] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ២៧ ។

គ្រាន់តែបានថ្លែងបញ្ជាក់ថា ការលើកលែងទោសដែលលោក **អៀង សារី** បានទទួលនោះគឺមិនអាចអនុវត្តនៅក្នុងករណីបច្ចុប្បន្ននេះបានទេ ពីព្រោះការលើកលែងទោសនោះយោងសំដៅតែទៅលើ **ច្បាប់ឆ្នាំ ១៩៩៤** ប៉ុណ្ណោះ និង "ក្រៅតែពីការលើកឡើងអំពីឧក្រិដ្ឋប្រល័យពូជសាសន៍នៅក្នុងបុព្វកថារបស់វា ច្បាប់នេះគ្រាន់តែយោងសំដៅទៅលើបទល្មើសមួយចំនួនដែលមានចែងនៅក្នុងច្បាប់ក្នុងស្រុកដែលជាកម្មវត្ថុនៃការចោទប្រកាន់ ស្របតាមច្បាប់ជាតិដែលអាចអនុវត្តបាន នៅពេលនោះ ក៏ដូចជាបទឧក្រិដ្ឋមួយក្រុមដែលប្រឆាំងនឹងសន្តិសុខរដ្ឋប៉ុណ្ណោះ។ ហេតុដូច្នេះ ទើបវាមិនគ្របដណ្តប់លើបទល្មើសទាំងឡាយដែលមានបង្ហាញនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក.[59]"។ ក.ស.ច.ស. មិនបានពន្យល់ពីរបៀបដែលខ្លួនបានឈានសម្រេចយកការសន្និដ្ឋាននោះទេ។

27. តាមពិត **ច្បាប់ឆ្នាំ ១៩៩៤** ប្រាកដជាគ្របដណ្តប់ទៅលើបទឧក្រិដ្ឋទាំងឡាយ ដែល"ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក."[60]។ អ.វ.ត.ក. មានយុត្តាធិការទៅលើបទឧក្រិដ្ឋមនុស្សឃាត អំពើធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញលើសាសនា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និង ឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ[61]។ បុព្វកថានៃ **ច្បាប់ឆ្នាំ ១៩៩៤** មិនមែនគ្រាន់តែ"និយាយសំដៅទៅលើអំពើប្រល័យពូជសាសន៍"ប៉ុណ្ណោះទេ ប៉ុន្តែវាបានចែងយ៉ាងច្បាស់ថា ច្បាប់នោះត្រូវបានអនុម័តឡើង "ដោយយល់ឃើញថាមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យមិនអាច... លាក់ខ្លួន ឬ រត់គេចពីការទទួលខុសត្រូវរបស់ពួកគេចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ ភេរវកម្ម និង អំពើប្រល័យពូជសាសន៍ ចាប់តាំងពីពេលដែលរបប ប៉ុល ពត បានឡើងកាន់អំណាចពីឆ្នាំ ១៩៧៥ ដល់ ១៩៧៨។ បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមានអាជ្ញាយុកាលទេ"[62]។

28. បុព្វកថាក៏បានពន្យល់ផងដែរថា ខ្មែរក្រហមបានប្រព្រឹត្តជាបន្តបន្ទាប់នូវ"ឧក្រិដ្ឋកម្ម ភេរវកម្ម និង អំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួនដណ្តើមយកអំណាចកាន់កាប់នៅខែមេសា ឆ្នាំ១៩៧៥ ជន្លៀសប្រជារាស្ត្រ ចាប់ខ្លួន សម្លាប់រង្គាល ហើយក្រោយមក លួចប្លន់ ដាក់មីនពាសវាលពាសព្រៃគ្រប់ទិសទី បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និង ទ្រព្យសម្បត្តិឯកជន ដឹកនាំកាប់សម្លាប់ប្រជារាស្ត្រ វាយទន្ទ្រានយកទឹកដីជាតិកាន់កាប់ដោយខុសច្បាប់ និង លក់

[59] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ ១៣ ។

[60] ដូចខាងលើ ។

[61] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣ ដល់ មាត្រា ៨ ។

[62] បុព្វកថានៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ឆ្នាំ ១៩៩៤ (បានបន្ថែមសេចក្តីបញ្ជាក់) ។

សម្បត្តិទ្រព្យធម្មជាតិដោយរំលោភទៅលើអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា[63]"។ ហេតុដូច្នេះ បទល្មើសដែលបានយោងសំដៅនៅក្នុងច្បាប់នេះមានលក្ខណៈទូលំទូលាយជាងការលើកឡើងរបស់ ក.ស.ច.ស. ។

29. មាត្រា៣ និង មាត្រា៤ នៃ ច្បាប់ ឆ្នាំ ១៩៩៤ ពណ៌នាបន្ថែមទៀតនូវបទឧក្រិដ្ឋដែលច្បាប់នេះមានបំណងគ្របដណ្តប់ មានរួម អំពើមនុស្សឃាតដោយចេតនា អំពើរំលោភសេពសន្ថវៈ អំពើប្លន់ អំពើបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និង ការកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ។ ការរៀបរាប់បទល្មើសនេះមិនទាន់អស់នៅឡើយទេព្រោះមាត្រា៣ បញ្ចប់ការរៀបរាប់បទល្មើសរបស់វាជាមួយពាក្យថា "។ល។"[64]។ បញ្ជីនេះមិនទាន់រៀបរាប់បទល្មើសអស់នៅឡើយ ដូចដែលមាត្រា៣ បានបញ្ចប់បញ្ជីបទល្មើសដោយវាក្យស័ព្ទថា "។ល។" ពីព្រោះបញ្ជីបទល្មើសមិនទាន់រៀបរាប់អស់ ដូច្នេះ គោលបំណងនិងវិសាលភាពនៃច្បាប់នោះ ដូចដែលបានពិភាក្សានៅក្នុងបុព្វកថា គួរត្រូវបានលើកយកមកគិតគូពិចារណា[65]។

30. មានការគាំទ្រយ៉ាងច្បាស់លាស់ផងដែរ ពីការអនុវត្តច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ចំពោះការចោទប្រកាន់សមាជិកខ្មែរក្រហមដទៃទៀតចំពោះបទឧក្រិដ្ឋមនុស្សឃាត ដែលគ្របដណ្តប់ទាំងស្រុងទៅលើបទល្មើសទាំងឡាយ ែដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ពោលគឺបទល្មើសដែលបានប្រព្រឹត្តនៅក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[66]។

---

[63] ដូចខាងលើ ។

[64] មាត្រា ៣ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ ១៩៩៤ ។

[65] ជាទូទៅ បុព្វកថាត្រូវបានគេយកមកពិចារណានៅពេលធ្វើការបកស្រាយច្បាប់។ សូមមើលឧទាហរណ៍រឿងក្តីរវាងរដ្ឋអាជ្ញាតទល់គ្នានឹង *Dyilo*, ICC-01/04-01/06 សាលក្រមស្តីពីពាក្យស្នើសុំរបស់រដ្ឋអាជ្ញាឱ្យធ្វើការពិនិត្យឡើងវិញជាវិសាមញ្ញនូវសេចក្តី សម្រេចចុះថ្ងៃ ទី៣១ ខែមីនា ឆ្នាំ២០០៦ របស់អង្គបុរេជំនុំជម្រះ I ដែលបានបដិសេធចំពោះការអនុញ្ញាតប្តឹងជំទាស់ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ ទំព័រ ១៣ ដល់ ១៤ "វិធានគ្របដណ្តប់លើការបកស្រាយផ្នែកណាមួយនៃច្បាប់គឺទម្ងន់ពាក្យពេចន៍ដែលត្រូវ ពិចារណានៅក្នុងបរិបទ និងនៅក្នុងស្មារតីនៃទិសដៅ និងគោលបំណងរបស់ច្បាប់។ បរិបទនៃបទប្បញ្ញត្តិរបស់ច្បាប់មួយត្រូវបានកំណត់និយមន័យដោយអនុផ្នែកជាក់លាក់ណាមួយរបស់ច្បាប់ ដែលត្រូវយល់ច្បាប់ទាំងមូលរួមផ្សំជាមួយនឹងផ្នែកនៃការអនុម័តច្បាប់ទាំងមូល។ គោលបំណងរបស់ច្បាប់អាចប្រមូលផ្តុំពីជំពូករបស់ច្បាប់ ដែលផ្នែកជាក់លាក់មួយអាចត្រូវបានដាក់បញ្ចូល និង <u>គោលដៅរបស់ច្បាប់ដែលបានពីគោលបំណងដ៏ទូលំទូលាយដែលអាចបានមកពីបុព្វកថារបស់ច្បាប់នេះ</u>"។ (<u>បានបន្ថែមសេចក្តីបញ្ជាក់</u>) ។

[66] មាត្រា១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

31. សវនាការកាត់ទោស *ឈ្យូក រិន* ជាសវនាការមួយក្នុងចំណោមសវនាការកាត់ទោសដែលពាក់ព័ន្ធនៅក្នុងការសម្លាប់ទេសចរបរទេសបីនាក់នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៤ គឺជារឿងក្តីដ៏សំខាន់បំផុតទាក់ទង ទៅនឹងការបកស្រាយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤[67]។ ប្រឈមមុខនឹងការផ្តន្ទាទោសពីបទមនុស្សឃាត ឈ្យូក រិន មានបំណងពឹងផ្អែកទៅលើបទប្បញ្ញត្តិច្បាប់ ស្តីពីការលើកលែងទោសដែលចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ដើម្បីការពារពីការផ្តន្ទាទោស ដោយហេតុថា គាត់បានចុះចូលជាមួយ រដ្ឋាភិបាលនៅក្នុងរយៈពេលប្រាំមួយខែនៃការចូលជាធរមានរបស់ច្បាប់នេះមាននៅក្នុងខែកក្កដា ឆ្នាំ ១៩៩៤[68]។ ចៅក្រមតុលាការក្រុងភ្នំពេញបានសម្រេចថា ឈ្យូក រិន គួរត្រូវបានដោះលែងភ្លាមៗ ព្រោះការចុះចូលរបស់គាត់មកជាមួយរដ្ឋាភិបាល បានផ្តល់អភ័យឯកសិទ្ធិឱ្យគាត់រួចពីការចោទប្រកាន់នៅក្រោមបទប្បញ្ញត្តិ ស្តីពីការលើកលែងទោសដែលចែងក្នុងមាត្រា៥[69]។ មានការពិភាក្សាយ៉ាងល្អិតល្អន់ មុនពេលបញ្ហានេះត្រូវបានសម្រេចនៅក្នុងសវនាការរបស់សាលាឧទ្ធរណ៍ កាលពីថ្ងៃ២៨ សីហា ឆ្នាំ២០០២[70]។ សាលាឧទ្ធរណ៍បានលើកឡើងថាបទប្បញ្ញត្តិដែលអនុគ្រោះទោសក្នុងរយៈពេលប្រាំមួយខែ "សំដៅទៅលើតែបទល្មើសដែលបានប្រព្រឹត្តមុនពេលច្បាប់នេះចូលជាធរមានប៉ុណ្ណោះ[71]"។

សេចក្តីសម្រេចបែបនេះហាក់ដូចជាបានយោងទាំងទៅលើការបកស្រាយសមហេតុផលនៃការចូលជា ធរមាននៃបទប្បញ្ញត្តិនេះ និងគោលបំណងរបស់អ្នកច្បាប់ដែលបានអនុម័តច្បាប់នេះ :

ក. ទីមួយ ដោយការអនុញ្ញាតឱ្យខ្មែរក្រហមប្រព្រឹត្តបទល្មើសនៅក្នុងរយៈពេលប្រាំមួយខែក្រោយច្បាប់នេះចូលជាធរមាន រួចហើយចុះចូលជាមួយរដ្ឋាភិបាលនៅក្នុងអំឡុងពេលនោះអាចនាំឱ្យ "ខ្មែរក្រហមកាប់សម្លាប់ និងលួចប្លន់តាមអំពើចិត្ត ឱ្យតែពួកគេបានចុះចូល

---

67 សូមមើលអត្ថបទរបស់ John A. Hall: *In the Shadow of the Khmer Rouge Tribunal: សវនាការក្នុងស្រុកកាត់ទោស នួន ប៉ែត ឈ្យូក រិន និង សំ ប៊ិត និងការស្វែងរកធម្មានុរូបតាមផ្លូវតុលាការនៅក្នុងប្រទេសកម្ពុជា មាត្រា៥ និង* PRAC. INT'L CTS. & TRIBUNALS 409 (2006).

68 ដូចខាងលើ ទំព័រ ៤៤៨ ដល់ ៤៤៩ ។

69 ដូចខាងលើ ទំព័រ ៤៥២ ។

70 Hall លេខយោង ៦៧ ទំព័រ ៤៥៧ យោង សាលាឧទ្ធរណ៍ក្រុងភ្នំពេញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៣/១៧.១០.២០០០ [ឈ្យូក រិន] សាលដីកាសាលាឧទ្ធរណ៍ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០២ សម្រង់សាលដីកា ។

71 ដូចគ្នាខាងលើ ទំព័រ ៤៦០ យោង សាលាឧទ្ធរណ៍ក្រុងភ្នំពេញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦៣/១៧.១០.២០០០ [ឈ្យូក រិន] សាលដីកាសាលាឧទ្ធរណ៍ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០២ សម្រង់សាលដីកា ទំព័រ ១៤ ។

មុនពេលនៃការ បញ្ចប់អំឡុងពេលអនុគ្រោះទោស"[72]។ វាអាចបង្កើតបានជាការអនុគ្រោះទោសជាមុនដ៏មាន ប្រសិទ្ធិភាពមួយសម្រាប់បទល្មើសដែលពុំទាន់បានប្រព្រឹត្តនៅឡើយ។

ខ. ទីពីរ អ្នកច្បាប់ដែលបានពាក់ព័ន្ធក្នុងការពិភាក្សាដេញដោយសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៩៤ បានផ្តល់ការបកស្រាយផ្សេងៗគ្នាយ៉ាងច្បាស់ ជាជាងការលើកឡើងរបស់តុលាការក្រុង។ អ្នកនយោបាយមកពីគណៈបក្សប្រឆាំង សម រង្ស៊ី ដែលធ្លាប់ធ្វើជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៩៤ និងបានចូលរួមពិភាក្សាដេញដោលក្នុងរដ្ឋសភាលើសេចក្តីព្រាងច្បាប់ស្តីពីការ ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ បានជំទាស់តវ៉ាថា ច្បាប់នេះមានគោលបំណងផ្តល់ការអនុគ្រោះទោសតែចំពោះបទល្មើស ដែលបានប្រព្រឹត្ត *មុន*ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើ ហើយថា រដ្ឋសភាបានគិតយ៉ាងច្បាស់លាស់ដល់បទល្មើសទាំងឡាយដែលបាន ប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[73]។ ហេតុដូចច្នេះ សាលដីកាដែលចេញដោយសាលាឧទ្ធរណ៍ដែលអះអាងថា ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ មានគោលបំណង អនុវត្តចំពោះតែបទល្មើសដែលបានប្រព្រឹត្តមុនការចូលជាធរមានរបស់ច្បាប់នេះ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ តែប៉ុណ្ណោះនោះ គឺជាសាលដីកាតែមួយគត់ដែលមេធាវីការពារបានលើកឡើងដោយផ្ទាល់ ទៅលើវិសាលភាពនៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ ។

32. មេធាវីការពារសូមលើកឡើងថា ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់មាន គោលបំណងជាច្បាប់ជាក់លាក់ដើម្បីធ្វើការផ្តន្ទាទោសបទល្មើស ដែលបានប្រព្រឹត្តដោយខ្មែរក្រហម ដែលជាមូលដ្ឋានច្បាប់តែមួយគត់ សម្រាប់ធ្វើការផ្តន្ទាទោសបទល្មើសសមាជិកក្រុមខ្មែរក្រហម[74]។ ដូចជា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជាប់ទាក់ទងទៅនឹងបទល្មើសដែលបានប្រព្រឹត្ត

---

[72] ដូចគ្នាខាងលើ ទំព័រ ៤៥៤ យោង Anette Marcher: មេធាវីសហរដ្ឋអាមេរិកសរសើរពីសាលដីកាផ្តន្ទាទោស ឈូក រិន ភ្នំពេញ ប៉ុស្តិ៍ អត្ថបទលេខចេញផ្សាយ ៩/១៧ សម្រាប់ថ្ងៃទី ១៨ ដល់ ៣១ ខែសីហា ឆ្នាំ២០០០។

[73] Gina Chon និង វ៉ាន់ រឿន: សាលដីកាផ្តន្ទាទោស ឈូក រិន បង្កើតបានជាយុត្តិសាស្ត្រមួយមិនច្បាស់លាស់សម្រាប់ខ្មែរក្រហម ដទៃទៀត កាសែត CAMBODIA DAILY ចេញថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០ ។

[74] ឧទាហរណ៍ សូមមើល Stan Starygin: តើ *Rudolph Höss* នៃកម្ពុជាគួរទទួលបានសិទ្ធិការពារតាមនីតិវិធីក្នុងកម្រិតអប្បបរមា ដែរឬទេ? CAMBODIAN L. REV. (ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ៥ ដល់ ៦។ នៅពេលពិភាក្សាពីការអនុគ្រោះទោស ដែលផ្តល់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ឆ្នាំ១៩៩៤ គាត់លើកឡើងថា "ច្បាប់ឆ្នាំ១៩៩៤ នេះ ផ្តល់សេចក្តីអត់ឱនទោសយ៉ាងធំធេង ដោយការលើកឡើងថា ការអនុគ្រោះនេះនឹងត្រូវបាន

ដោយសមជិកក្រុម ខ្មែរក្រហម។ ការបកស្រាយផ្ទុយពីនេះអាចមានន័យថា បទប្បញ្ញត្តិស្តីពីការអនុគ្រោះទោសមិនមានសារៈប្រយោជន៍អ្វីទាល់តែសោះ ដែលជាខែលប្រឆាំងនឹងការផ្តន្ទាទោសនៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ សូម្បីតែវាអាចការពារពីការចោទប្រកាន់នៅក្រោមច្បាប់ឆ្នាំ ១៩៩៤ក៏ដោយ។ បើដូច្នេះមែន ការផ្តល់ការអនុគ្រោះទោសនៅក្រោមមាត្រា ៥ មិនអាចទទួលបានជោគជ័យនៅក្នុងការបញ្ចុះបញ្ចូល សមាជិកក្រុមខ្មែរក្រហមឲ្យចុះចូលបានឡើយ។

33. ច្បាប់ឆ្នាំ១៩៩៤ និង ការអនុគ្រោះនិងការលើកលែងទោស គឺជាដំណោះស្រាយថ្នាក់ជាតិ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ និងដោយមានការគាំទ្រពីសភាជាតិនិងដោយមានសំណើពីនាយករដ្ឋមន្ត្រីទាំងពីរ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលដែលបានញាំញីប្រទេសកម្ពុជារយៈពេល ២៥ឆ្នាំ[75] ។ កិច្ចប៉ុនប៉ងដើម្បីបញ្ចប់សង្គ្រាមស៊ីវិល[76] និងចាប់ផ្តើមដំណើរការផ្សះផ្សារជាតិ រួមផ្សំជាមួយការផ្តន្ទាទោសសមាជិកនៅក្នុងក្រុមកម្ពុជាប្រជាធិបតេយ្យដែលនៅក្រៅច្បាប់ ដោយអនុគ្រោះទុកពេល៦ខែ ក្រោយពីចូលជាធរមាននៃច្បាប់នេះ ។

---

ពង្រីកដោយរាប់បញ្ចូល 'បទល្មើសដែល ពួកគេ [សមាជិកនៃអង្គការចាត់តាំងនយោបាយ និងយោធារបស់កម្ពុជាប្រជាធិបតេយ្យ] បានប្រព្រឹត្ត' ដោយមិនកំណត់ប្រយោគ នេះជាបណ្តោះអាសន្ន ឬហាមឃាត់ប្រយោគនេះទៅនឹងលក្ខខណ្ឌជាទម្ងន់ណាមួយនោះឡើយ... ។ ទោះបីជាច្បាប់នេះជាពុំមានការ ចោទជាសំណួរថា <u>'អំពើប្រល័យពូជសាសន៍' និងបទល្មើសប្រឆាំងនឹងមនុស្សធម៌ដទៃទៀតដែលបានរៀបរាប់នៅក្នុងបុព្វកថា</u>នៃ ច្បាប់ឆ្នាំ ១៩៩៤ ត្រូវបានចាត់ទុកថាជា jus cogens និងអាចផ្តន្ទាទោសនៅក្រោមច្បាប់ប្រពៃណីអន្តជាតិក៏ដោយ ក៏បទល្មើសទាំង នេះមិនអាចផ្តន្ទាទោសនៅក្រោមយុត្តាធិការនេះបានទេ [ដោយសារតែការអនុគ្រោះទោសដែលមានចែងក្នុងមាត្រា ៥] <u>(បានបន្ថែម សេចក្តីបញ្ជាក់)</u>។

[75] នៅពេលពិភាក្សានិងអនុវត្តច្បាប់ឆ្នាំ១៩៩៤ ខ្មែរក្រហមនៅមានសកម្មភាពខ្លាំងនៅឡើង ហើយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសត្រូវបានបរាជ័យ ។ សូមមើលរបាយការណ៍ដំបូងរបស់រដ្ឋជាភាគីនៅឆ្នាំ១៩៩៣ៈ កម្ពុជា ។ 23/09/98. CCPR/81/Add.12. (របាយការណ៍របស់រដ្ឋជាភាគី) កម្មាធិការសិទ្ធិមនុស្សពិចារណារបាយការណ៍ដែលបញ្ជូនដោយរដ្ឋជាភាគី ក្រោមមាត្រា ៤០ នៃកតិការសញ្ញា CCPR កថាខណ្ឌទី ៩៥ ។ "ខ្មែរក្រហម ដែលជាហត្ថលេខីមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មិនបានរំសាយកងទ័ព ប្រមូលផ្តុំកងទ័ពនៅនឹងកន្លែង ឬ ដកហូតអាវុធពីកងទ័ពរបស់ខ្លួន ក្រោមការត្រួតពិនិត្យដោយតំណាងរបស់អង្គការសហប្រជាជាតិ ។ ពួកគេលាក់ទុកអាវុធ និងពន្ធ្យាសង្គ្រាម ដោយបន្តរការបំផ្លិតបំផ្លាញ និងគំរាមកំហែងដល់សន្តិសុខ ។ ពួកគេនៅបន្តរកាប់សំលាប់ជនស៊ីវិល និងមន្ត្រីដើម្បីធ្វើយុទ្ធនាការប្រឆាំរាជរដ្ឋាភិបាល និងអនុវត្តគោលនយោបាយជាតិសាសន៍និយម" ។

[76] ដូចលេខយោង ១០៥ ខាងលើ "រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ <u>ក្នុងគោលបំណងបញ្ចប់សង្គ្រាម</u> និងដាក់ទណ្ឌកម្មពួកបោះបោរ ដែលបន្តរប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងប្រជាជន" ។ (<u>បញ្ជាក់បន្ថែម</u>)

34. ការអនុគ្រោះ និងការលើកលែងទោសដល់លោក **អៀង សារី** កាលពីឆ្នាំ១៩៩៦ គឺជាសេចក្តីសម្រេចដោយរដ្ឋាភិបាលដ៏ត្រឹមត្រូវមួយ ប្រកបដោយនីត្យានុកូលភាពតាមបែបលទ្ធិប្រជាធិបតេយ្យ[77] ហើយវាគឺជាសេចក្តីសម្រេចចុងក្រោយប្រកបដោយជ័យជំនះ ក្នុងការនាំមកនូវសន្តិភាព និងស្ថិរភាពដល់ប្រទេសជាតិ ។ ជាការពិតណាស់ នៅក្នុងបទសម្ភាសន៍ជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា កាលពីឆ្នាំ១៩៩៩ សម្តេចមានប្រកាសថា"ប្រសិនបើគ្មានលោក **អៀង សារី** ដឹកនាំយោធាខ្មែរក្រហម ៧០ភាគរយ ធ្វើសមាហរណកម្មជាមួយកងទ័ពរដ្ឋាភិបាលទេ នោះសង្គ្រាមនឹងមិនបញ្ចប់ឡើយ"[78] ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការពន្យល់បន្ថែមទៀតថា "ប្រសិនបើមានការប៉ុនប៉ងណាមួយដើម្បីកាត់ទោសលោក **អៀង សារី** វាអាចបង្កឲ្យមានសង្គ្រាមម្តងទៀត ដែលនេះមិនមែនជាចេតនាល្អឡើយ ។ វាជាក្បត់នឹងសន្តិភាព និងផ្សះផ្សារជាតិ"[79] ។

---

[77] ដូចខាងលើ កថាខណ្ឌទី ១០១ "ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ដែលត្រូវបានអនុម័តដោយសភាជាតិនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៤ គឺជាច្បាប់ពិសេសមួយដែលមានបំរើផលប្រយោជន៍ឲ្យសន្តិភាព និង បញ្ចប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ច្បាប់នេះអនុវត្តចំពោះតែប្រជាជនកម្ពុជាមួយក្រុមដែលប្រឆាំងនឹងឆន្ទះដ៏មានប្រជាប្រិយ (មាត្រា ២ នៃច្បាប់) និងពុំមានបទបញ្ញត្តិដែលប៉ះពាល់ និងរឹតបណ្តឹងដល់សិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋឡើយ (មាត្រា ៩)។ ជាសេចក្តីសរុប ច្បាប់នេះមិនបានធ្វើឲ្យហួសពីដែនកំណត់ដែលអនុញ្ញាតដោយកតិកាសញ្ញាឡើយ តែវាបានរក្សាកាលៈទេសៈ និង ស្ថានភាពនៅកម្ពុជា" ។

[78] សូមមើលអត្ថបទព័ត៌មាន៖ *ច្បាប់កាត់ទោសខ្មែរក្រហមនឹងអនុម័តនៅខែធ្នូ: នាយករដ្ឋមន្ត្រីកម្ពុជា* ដោយ AGENCE FRANCE-PRESS, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ។

[79] ការលើកលែងទោសដែលបានចូលរួមចំណែកដល់សន្តិភាព ឬ ទប់ស្កាត់ការវិលត្រឡប់នូវជម្លោះ ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ដល់ប្រទេសដែលពាក់ព័ន្ធ ហើយក៏ប្រហែលជាមិនចង់ឲ្យបាត់បង់ទៅវិញដោយស្រួលដោយអ្នកក្រៅដែរ ដែលមិនបានទទួលរងនូវការឈឺចាប់បង្កឡើងដោយបញ្ហាទាំងនេះ និងមិនបានទទួលនូវអត្ថប្រយោជន៍ពីការអនុគ្រោះ និងលើកលែងទោសបែបនេះ ។ កំណត់សំគាល់ដោយលោក នៅ កាស៊ី និង Jeffery C. Gallup នៅក្នុងអត្ថបទក្រោមចំណងជើងថា "*សិទ្ធិមនុស្សនិងអតីតកាលនៅកម្ពុជា: ការពារសន្តិភាព មុនយុត្តិធម៌*", (In Defense of Peace Before Justice), HUM. RTS. DIALOGUE 1.8 (1997):

> ប្រជាជនមិនត្រឹមតែស្រុះស្រួលទេ ប៉ុន្តែថែមទាំងគាំទ្រដល់ការលើកលែងរបស់រដ្ឋាភិបាលទៀតផង។ការស្ទង់មតិមួយដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកឈ្មោះ Solidarity and Community Development Association (SODECO) ផ្សព្វផ្សាយនៅខែមករា ឆ្នាំ១៩៩៧ ដោយកាសែតកម្ពុជាដេលី រាយការណ៍ថាចំនួន២ភាគបីនៃអ្នកសម្ភាសន៍ ១១២០នាក់ "ពេញចិត្ត" ដំណោះស្រាយជាមួយលោក អៀង សារី ហើយការស្ទង់មតិតាមផ្លូវផ្លូវរបស់កាសែតភ្នំពេញប៉ុស ដែលផ្សព្វផ្សាយនៅលេខផ្សាយ ២៣ សីហា ដល់ ៥ កញ្ញា ១៩៩៦ បង្ហាញពីលទ្ធផលស្រដៀងគ្នា ។ (អង្គការ SODECO មានសម្ព័ន្ធភាពជិតស្និទ្ធជាមួយមេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី)... ជារួមមក ការខកខានរបស់រដ្ឋាភិបាលកម្ពុជាដើម្បីនាំពួកខ្មែរក្រហមមកប្រឈមជាមួយយុត្តិធម៌ ឆ្លុះបញ្ចាំងទាំងផលប្រយោជន៍

35. ការលើកលែងទោសលោក **អៀង សារី** ផ្តល់អភ័យឯកសិទ្ធិពិសេសដល់ **អៀង សារី** ឱ្យរួចផុតពីការចោទប្រកាន់ចំពោះបទល្មើសដែលបានកំណត់ដោយច្បាប់ឆ្នាំ១៩៩៤[80] ហើយបទល្មើសទាំងនេះគឺដូចយ៉ាងច្បាស់ទៅនឹងបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ហេតុដូច្នេះ ច្បាប់ឆ្នាំ១៩៩៤ រារាំងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញទៅលើលោក **អៀង សារី** ទាក់ទងនឹងបទល្មើសទាំងនោះ ។

## V. សេចក្តីសន្និដ្ឋាន និង ការស្នើរកដំណោះស្រាយ

**អាស្រ័យហេតុនេះ** រាល់មូលហេតុដូចដែលមានបញ្ជាក់ជូននៅទីនេះ មេធាវីការពារស្នើសុំដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះ មេត្តា:

(ក) ប្រកាសថា សវនាការឆ្នាំ១៩៧៩ លើលោក **អៀង សារី** បង្កាលោក **អៀង សារី** ពីការស៊ើបអង្កេត និងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ស្របតាមគោលការណ៍ *ne bis idem* និង

(ខ) ប្រកាសថា ព្រះរាជទានការអនុគ្រោះ និងលើកលែងទោសឱ្យលោក **អៀង សារី** កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ គឺស្របច្បាប់ មានសុពលភាព និង អាចអនុវត្តបាន ហើយរារាំងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញលើលោក **អៀង សារី** ។

---

ពិតៗនិងឧបសគ្គខាងនយោបាយ។ ការអនុគ្រោះ លោក អៀង សារី ពិតជាជួបនូវការលំបាកមែន ប៉ុន្តែហេតុផលរបស់វា ត្រូវបានទទួលយកដោយប្រជាជនដែលស្រេកឃ្លាននូវសន្តិភាព ។នៅទីបញ្ចប់ រដ្ឋាភិបាលកម្ពុជាផ្តល់ការឆ្លើយតបដល់ប្រជាជនក្នុងស្រុកចំពោះកាលៈទេសៈក្នុងស្រុកៈ វិធានការរបស់រដ្ឋាភិបាលមិនបានឆ្លើយតបគោលការណ៍ទូទៅ ឬ ក៏មិនបានបំពេញបំណងសហគមន៍អន្តរជាតិដែរ ប៉ុន្តែគឺធ្វើឡើង សម្រាប់តែអនាគតរបស់កម្ពុជាតែប៉ុណ្ណោះ ។ វាជាជំរើសសន្តិភាព ជាជាងយុត្តិធម៌ ។

សូមមើលផងដែរនូវអត្ថបទរបស់ Louise Mallinder ដែលមានចំណងជើងថា *"តើការលើកលែងទោស និងយុត្តិធម៌អន្តរជាតិអាចផ្សះផ្សារគ្នាបានទេ?" (Can Amnesty and International Justice be Reconciled?)*, INT'L J. TRANSITIONAL JUST.2008 (2007) អត្ថបទរបស់លោក Arsanjani, លេខយោង ១៤ ខាងលើ ។ សម្រាប់បញ្ជីសន្ធិសញ្ញាអន្តរជាតិដែលចុះហត្ថលេខានៅសតវត្សទី១៧, ១៨ និងទី១៩ ដែលរួមបញ្ចូលបទបញ្ញត្តិស្តីពីការលើកលែងទោស ផងដែរ ។ សូមមើលអត្ថបទរបស់ Fania Domb ក្រោមចំណងជើងថា Treatment of War Crimes in Peace Settlement- Prosecution or Amnesty? 24 ISRAEL. Y.B. HUM. RTS.253-254-55 (1994).

[80] មាតត្រា ១ នៃច្បាប់ឆ្នាំ១៩៩៤ ។

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អបជ(០៣)

C22/I/26

សូមលោកចៅក្រមទទួលសារណាដោយក្តីគោរព ។

ធ្វើនៅភ្នំពេញរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨

មេធាវី អាង ឧត្តម      មេធាវី Michael G. KARNAVAS

សហមេធាវីការពារលោក អៀង សារី